មាត្រា ១៦ ._ ការចុះ និង ការអនុវត្តនូវកិច្ចសន្យាដោយចំការកៅស៊ូមេមត់ ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ ._ ចំការកៅស៊ូមេមត់ កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨ .- -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ ចំការកៅស៊ូមេមត់ ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ចំការកៅស៊ូមេមត់ ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៩ .**_ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ចំការកៅស៊ូមេមត់ ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ ចំការកៅស៊ូមេមត់ ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ចំការកៅស៊ូមេមត់ ។

**មាត្រា ២០ .**_ ធនធាននៃ ចំការកៅស៊ូមេមត់ ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ចំការកៅស៊ូមេមត់

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ចំការកៅស៊ូមេមត់

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

**មាត្រា ២១ .**_ ចំណាយនៃ ចំការកៅស៊ូមេមត់ រួមមាន :

+ ចំណាយប្រព្រឹត្តិសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

**មាត្រា ២២ .**_ ចំការកៅស៊ូមេមត់ អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា ២៣ .**_ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល ចំការកៅស៊ូមេមត់ ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ ចំការកៅស៊ូមេមត់ មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

មាត្រា ២៤ ._ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៥._ រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ចំការកៅស៊ូមេមត់ ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)
- របាយការណ៍ស្តីពីសកម្មភាព-ពុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូមេមត់
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

មាត្រា ២៦ ._ ត្រូវបានដាក់ឲ្យនៅអម ចំការកៅស៊ូមេមត់ នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

មាត្រា ២៧ ._ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
**ឈា សុខ**

★★★

## អនុក្រឹត្យលេខ ១៨ អនក្រ.បក

## ស្តីពីការបង្កើត ចំការកៅស៊ូជប់

## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការឯកភាពពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។

## សម្រេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.**_ ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូជុបឱ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូជុប** សរសេរកាត់ "ច ក ជ " ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូជុប** មានទីស្នាក់ការនៅភូមិជុប ឃុំជុប ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម
- **ចំការកៅស៊ូជុប** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

**មាត្រា ២ .**_ **ចំការកៅស៊ូជុប** មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ **ចំការកៅស៊ូជុប** មានភារកិច្ច និង កាតព្វកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឱ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់ គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឱ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការលើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម-ផលិតកម្ម ។

- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

**មាត្រា ៣ ._** ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **ចំការកៅស៊ូជុប** ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ **ចំការកៅស៊ូជុប** ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

**មាត្រា ៤ .-** **ចំការកៅស៊ូជប់** ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើតចំការកៅស៊ូជុប

៣-លក្ខន្តិកៈ **ចំការកៅស៊ូជុប**

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

**មាត្រា ៥ ._** **ចំការកៅស៊ូជុប** ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ៦ ._** ដើមទុនដំបូងនៃ **ចំការកៅស៊ូជុប** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន **ចំការកៅស៊ូជប់** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៧ ._** បុគ្គលិករបស់ **ចំការកៅស៊ូជប់** ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូជុប។

បុគ្គលិករបស់ **ចំការកៅស៊ូជុប** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២
## ការដឹកនាំនិងគ្រប់គ្រង

**មាត្រា ៨ ._** **ចំការកៅស៊ូជុប** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក **ចំការកៅស៊ូជុប** | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |
| + តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ | ១ រូប | ជាសមាជិក |
| + តំណាងនិយោជិតរបស់ **ចំការកៅស៊ូជុប** | ១ រូប | ជាសមាជិកស្វ័យប្រវត្តិ |

**មាត្រា ៩ .** -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរ ដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត **ចំការកៅស៊ូជុប**

**មាត្រា ១០ ._** ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម **ចំការកៅស៊ូជុប** ក្នុងការរៀបចំលិខិតស្នាម និងរាល់រឿងរ៉ាវផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្ដល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ចំការកៅស៊ូជុប** ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ **ចំការកៅស៊ូជុប** ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្ដល់ការយល់ព្រមលើកិច្ចសន្យាដែល **ចំការកៅស៊ូជុប** ជាភាគីត្រូវតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ញត្តិជាធរមាន ស្ដីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ ចំការកៅស៊ូជុប តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ។

**មាត្រា ១១.**_ -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំង ឯកសារទាក់ទិនទាំងឡាយ ត្រូវធ្វើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារ កូរ៉ុមទេ ។

-សេចក្ដីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២._ សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក **ចំការកៅស៊ូជុប** ។

មាត្រា ១៣._ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ **ចំការកៅស៊ូជុប** និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ :

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលតាមតំណាក់កាលនីមួយៗ បធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ចំការកៅស៊ូជុប** ។

២-ទទួលដឹកនាំ **ចំការកៅស៊ូជុប** លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ **ចំការកៅស៊ូជុប** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ចំការកៅស៊ូជុប** ដោយអនុវត្តតាមលក្ខន្តិកៈ បុគ្គលិក ឬ ច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ **ចំការកៅស៊ូជុប** ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ឥវ៉ាការពារក្តីឲ្យ **ចំការកៅស៊ូជុប** និងការប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៥ .**_ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៦ .**_ ការចុះ និង ការអនុវត្តន៍កិច្ចសន្យាដោយ **ចំការកៅស៊ូជុប** ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៧ .**_ **ចំការកៅស៊ូជុប** កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញត្តិគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

**មាត្រា ១៨.**_ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ **ចំការកៅស៊ូជុប** ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូជុប** ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ចំការកៅស៊ូជុប ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ ចំការកៅស៊ូជុប ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ចំការកៅស៊ូជុប ។

មាត្រា ២០ ._ ធនធាននៃ ចំការកៅស៊ូជុប ជារាទ៏មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ចំការកៅស៊ូជុប ។

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុអចលនវត្ថុរបស់ ចំការកៅស៊ូជុប ។

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

មាត្រា ២១ ._ ចំណាយនៃ ចំការកៅស៊ូជុប រួមមាន :

+ ចំណាយប្រក្រតីសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

មាត្រា ២២ ._ ចំការកៅស៊ូជុប អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២៣._ ជារៀងរាល់ឆ្នាំ ក្រោយពីកេនការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល ចំការកៅស៊ូជុប ទទួលបានក្រោយ

ពីការទូទាត់ ស្របតាមវិធានគណនេយ្យ **ចំការកៅស៊ូជុប** មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

**មាត្រា ២៤ .–** រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ជំពូក ៤**

**ការទំនាក់ទំនងជាមួយរដ្ឋ**

**មាត្រា ២៥ .–** រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ចំការកៅស៊ូជុប** ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៨)
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូជុប
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

**មាត្រា ២៦ .–** ត្រូវបានដាក់ឲ្យនៅអម **ចំការកៅស៊ូជុប** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**ជំពូក ៥**

**អវសានបញ្ញត្តិ**

**មាត្រា ២៧ .–** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨ .–** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន

មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
ឈាន សុខ

★★★

## អនុក្រឹត្យលេខ ១៥ អនក្រ.បក
## ស្តីពីការបង្កើត ចំការកៅស៊ូក្រេក
## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

## សំរេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.**_ ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូព្រែកក្ឆ្សទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូក្រែក** សរសេរកាត់ "ច ក ក " ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូក្រែក** មានទីស្នាក់ការស្ថិតនៅទីរួមស្រុកពញាក្រែក ខេត្តកំពង់ចាម ។
- **ចំការកៅស៊ូក្រែក** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

**មាត្រា ២ .**_ **ចំការកៅស៊ូក្រែក** មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ **ចំការកៅស៊ូក្រែក** មានភារកិច្ច និង ភាតព្វកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងតំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការបើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធក្នុងការធ្វើអាជីវកម្ម-ផលិតកម្ម ។

- លើកកំពោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

**មាត្រា ៣ ._** ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **ចំការកៅស៊ូក្រែក** ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹងពាណិជ្ជកម្មទូទៅ ។ ក្នុងន័យនេះ **ចំការកៅស៊ូក្រែក** ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង្ស និងមានការរីកចំរើន ។

**មាត្រា ៤ ._** **ចំការកៅស៊ូក្រែក** ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ÷

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត **ចំការកៅស៊ូក្រែក**

៣-លក្ខន្តិកៈ **ចំការកៅស៊ូក្រែក**

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

**មាត្រា ៥ ._** **ចំការកៅស៊ូក្រែក** ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ៦ ._** ដើមទុនដំបូងនៃ **ចំការកៅស៊ូក្រែក** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន **ចំការកៅស៊ូក្រែក** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៧ ._** បុគ្គលិករបស់ **ចំការកៅស៊ូក្រែក** ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូក្រែក ។

បុគ្គលិករបស់ **ចំការកៅស៊ូក្រែក** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២
## ការដឹកនាំនិងគ្រប់គ្រង

មាត្រា ៨ ._ **ចំការកៅស៊ូក្រែក** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក **ចំការកៅស៊ូក្រែក** | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |
| + តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ | ១ រូប | ជាសមាជិក |
| + តំណាងនិយោជិតរបស់ **ចំការកៅស៊ូក្រែក** | ១ រូប | ជាសមាជិកស្វ័យប្រវត្តិ |

មាត្រា ៩._ -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត **ចំការកៅស៊ូក្រែក**

មាត្រា ១០ ._ ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម **ចំការកៅស៊ូក្រែក** ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើគុណ្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ចំការកៅស៊ូក្រែក** ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលេខ្ខន្តិកៈផ្ទៃក្នុងរបស់ **ចំការកៅស៊ូក្រែក** ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល **ចំការកៅស៊ូក្រែក** ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ **ចំការកៅស៊ូក្រែក** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

**មាត្រា ១១ .** -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា ១២.**_ សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុអង្គប្រជុំ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក **ចំការកៅស៊ូក្រែក** ។

**មាត្រា ១៣ .**_ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ **ចំការកៅស៊ូក្រែក** និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

**មាត្រា ១៤.**_ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ :

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមដំណាក់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ **ចំការកៅស៊ូក្រែក** ។

២-ទទួលដឹកនាំ **ចំការកៅស៊ូក្រែក** លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ **ចំការកៅស៊ូក្រែក** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ចំការកៅស៊ូក្រែក** ដោយអនុវត្តតាមលក្ខន្តិកៈ បុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ **ចំការកៅស៊ូក្រែក** ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ត៌វ៉ាការពារក្តីឲ្យ **ចំការកៅស៊ូក្រែក** និងការប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៥ .**_ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុម ប្រឹក្សាភិបាល ។

មាត្រា ១៦ ._ ការចុះ និង ការអនុវត្តន៍កិច្ចសន្យាដោយ **ចំការកៅស៊ូក្រែក** ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ ._ **ចំការកៅស៊ូក្រែក** កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ **ចំការកៅស៊ូក្រែក** ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូក្រែក** ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៩ .**_ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ឱកាសសំរាប់ដំណើរការនៃ **ចំការកៅស៊ូក្រែក** ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ **ចំការកៅស៊ូក្រែក** ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់**ចំការកៅស៊ូក្រែក** ។

**មាត្រា ២០ .**_ ធនធាននៃ **ចំការកៅស៊ូក្រែក** ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **ចំការកៅស៊ូក្រែក** ។

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ **ចំការកៅស៊ូក្រែក** ។

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

**មាត្រា ២១ .**_ ចំណាយនៃ **ចំការកៅស៊ូក្រែក** រួមមាន :

+ ចំណាយប្រក្រតីសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

**មាត្រា ២២ .**_ **ចំការកៅស៊ូក្រែក** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា ២៣.**_ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល **ចំការកៅស៊ូក្រែក** ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ **ចំការកៅស៊ូក្រែក** មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

**មាត្រា ២៤ .**_ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤
## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៥ .**_ របេះពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ចំការកៅស៊ូក្រែក ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- ត់រោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)
- របាយការណ៍ស្តីពីសកម្មភាព-គុណូការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូក្រែក
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

**មាត្រា ២៦ :** ត្រូវបានដាក់ឲ្យនៅអម ចំការកៅស៊ូក្រែក នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណោទនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥
## អវសានបញ្ញត្តិ

**មាត្រា ២៧ .**_ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

| | |
|---|---|
| ទេសរដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ហត្ថលេខា | ហត្ថលេខា |
| **គាត ឈន់** | **ឈា សុខ** |

***

# អនុក្រឹត្យលេខ ១៦ អនក្រ.បក
## ស្ដីពីការបង្កើត ចំការកៅស៊ូចំការពាមជាំង
## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១-៩៦-១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

## សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

មាត្រា ១._ ត្រូវបានកែប្រែអង្គភាពស្វ័យភាពរដ្ឋបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូពាមជាំងឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូពាម**

ជាំង សរសេរកាត់ "ច ក ត ជ" ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូតាមជាំង** មានទីស្នាក់ការស្ថិតនៅ ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តកំពង់ចាម
- **ចំការកៅស៊ូតាមជាំង** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

មាត្រា ២._ **ចំការកៅស៊ូតាមជាំង** មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ **ចំការកៅស៊ូតាមជាំង** មានភារកិច្ច និង ភារព្វកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានគ្រប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានដែលកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការលើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធក្នុងការធ្វើអាជីវកម្ម-ផលិតកម្ម ។
- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារូមភាពកិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលទាក់ទាញដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

មាត្រា ៣._ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **ចំការកៅស៊ូតាមជាំង** ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ **ចំការកៅស៊ូតាមជាំង** ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ

ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

**មាត្រា ៤ ._** **ចំការកៅស៊ូពាមជាំង** ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត **ចំការកៅស៊ូពាមជាំង**

៣-លក្ខន្តិកៈ **ចំការកៅស៊ូពាមជាំង**

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

**មាត្រា ៥ ._** **ចំការកៅស៊ូពាមជាំង** ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ៦ ._** ដើមទុនដំបូងនៃ **ចំការកៅស៊ូពាមជាំង** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន **ចំការកៅស៊ូពាមជាំង** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៧ ._** បុគ្គលិករបស់ **ចំការកៅស៊ូពាមជាំង** ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូពាមជាំង ។

បុគ្គលិករបស់ **ចំការកៅស៊ូពាមជាំង** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២
## ការដឹកនាំនិងគ្រប់គ្រង

**មាត្រា ៨ ._** **ចំការកៅស៊ូពាមជាំង** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក **ចំការកៅស៊ូពាមជាំង** | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |

+ តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ ១ រូប ជាសមាជិក

+ តំណាងនិយោជិតរបស់ **ចំការកៅស៊ូតាមជាំង** ១ រូប ជាសមាជិកស្វ័យប្រវត្តិ

មាត្រា ៩ .- -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។

- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត **ចំការកៅស៊ូតាមជាំង**

មាត្រា ១០ .- ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម **ចំការកៅស៊ូតាមជាំង** ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ចំការកៅស៊ូតាមជាំង** ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ **ចំការកៅស៊ូតាមជាំង** ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល **ចំការកៅស៊ូតាមជាំង** ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និង បែបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ **ចំការកៅស៊ូតាមជាំង** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចពើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ប្រក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ។

មាត្រា ១១ ._ -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានចំនួនយ៉ាងតិច ពាក់កណ្តាលក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារពាក់ព័ន្ធទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំចាំបាច់មានការកូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២._ សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខាធិការអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក **ចំការកៅស៊ូចាមការលើ** ។

មាត្រា ១៣ ._ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ **ចំការកៅស៊ូចាមការលើ** និងត្រូវបានតែងតាំង សំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ ៖

១-រៀបចំរកការទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមកំណត់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ចំការកៅស៊ូតាមដាំង** ។

២-ទទួលដឹកនាំ **ចំការកៅស៊ូតាមដាំង** លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ **ចំការកៅស៊ូតាមដាំង** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាផ្ទេរពុក្រា បណ្ដាភ្នាក់ងារឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់**ចំការកៅស៊ូតាមដាំង** ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ **ចំការកៅស៊ូតាមដាំង** ចំពោះមុខតុលាការ និងគណៈកម្មការស្រេចក្ដីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ពីការពារក្ដីឲ្យ **ចំការកៅស៊ូតាមដាំង** និងការប្ដឹងជំទាស់ផ្សេងៗ ។

មាត្រា ១៥ ._ បៀវត្សការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៦ ._ ការចុះ និង ការអនុវត្តកិច្ចសន្យាដោយ **ចំការកៅស៊ូតាមដាំង** ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ ._ **ចំការកៅស៊ូតាមដាំង** កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញត្តគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្ដើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) លើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ ៣ ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ **ចំការកៅស៊ូតាមបាំង** ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូតាមបាំង** ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្ដល់ការយល់ព្រមលើចំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយក ហើយបញ្ជូនចំរោងនេះដើម្បី សុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូតាមដាំង** ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ **ចំការកៅស៊ូតាមដាំង** ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូតាមដាំង** ។

**មាត្រា ២០ ._** ធនធាននៃ **ចំការកៅស៊ូតាមដាំង** ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។
+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។
+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **ចំការកៅស៊ូតាមដាំង** ។
+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុនិង អចលនវត្ថុរបស់ **ចំការកៅស៊ូតាមដាំង** ។
+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

**មាត្រា ២១ ._** ចំណាយនៃ **ចំការកៅស៊ូតាមដាំង** រួមមាន :

+ ចំណាយប្រព្រឹត្តទៅសំរាប់ដំណើរការ
+ ចំណាយវិនិយោគ
+ ចំណាយសងការប្រាក់ និងដើមទុន
+ សងបំណុល
+ ចំណាយផ្សេងៗ

**មាត្រា ២២ ._** **ចំការកៅស៊ូតាមដាំង** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់ប្រតិបត្តិការរបស់ខ្លួន ។

**មាត្រា ២៣ ._** ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រាក់ចំណេញដែល **ចំការកៅស៊ូតាមដាំង** ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ **ចំការកៅស៊ូតាមដាំង** មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះ ឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

**មាត្រា ២៤ ._** រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៥ ._** រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ចំការកៅស៊ូតាមដាំង** ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)

- របាយការណ៍ស្តីពីសកម្មភាព-គុណភាព និងតួនាទីគ្រប់គ្រងទាំងឡាយរបស់ **ចំការកៅស៊ូតាមដាំង**

- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការរដ្ឋាភិបាល ។

**មាត្រា ២៦ ._** ត្រូវបានដាក់ឲ្យនៅអម **ចំការកៅស៊ូតាមដាំង** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

**មាត្រា ២៧ ._** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

| | |
|---|---|
| ទេសរដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ហត្ថលេខា | ហត្ថលេខា |
| **គាត ឈន់** | **ឈាន សុខ** |

★★★

## អនុក្រឹត្យលេខ ១៧ អនក្រ.បក
## ស្តីពីការបង្កើត ចំការកៅស៊ូបឹងកេត
## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានបានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

## សំរេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-** ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូបឹងកេតឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូបឹង**

កេត សរសេរកាត់ "ច ក ម ក " ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូមីមោត** មានទីស្នាក់ការស្ថិតនៅឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។
- **ចំការកៅស៊ូមីមោត** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

មាត្រា ២ ._ **ចំការកៅស៊ូមីមោត** មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញ នូវកម្មវត្ថុខាងលើនេះ **ចំការកៅស៊ូមីមោត** មានភារកិច្ច និង ភារកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការលើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម-ផលិតកម្ម ។
- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្ដីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

មាត្រា ៣ ._ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **ចំការកៅស៊ូមីមោត** ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ **ចំការកៅស៊ូមីមោត** ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ

ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

**មាត្រា ៤ .-** **ចំការកៅស៊ូបឹងកេត** ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត **ចំការកៅស៊ូបឹងកេត**

៣-លក្ខន្តិកៈ **ចំការកៅស៊ូបឹងកេត**

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

**មាត្រា ៥ .-** **ចំការកៅស៊ូបឹងកេត** ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ៦ .-** ដើមទុនដំបូងនៃ **ចំការកៅស៊ូបឹងកេត** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន **ចំការកៅស៊ូបឹងកេត** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៧ .-** បុគ្គលិករបស់ **ចំការកៅស៊ូបឹងកេត** ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូបឹងកេត ។

បុគ្គលិករបស់ **ចំការកៅស៊ូបឹងកេត** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២

## ការដឹកនាំនិងគ្រប់គ្រង

**មាត្រា ៨ .-** **ចំការកៅស៊ូបឹងកេត** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក **ចំការកៅស៊ូបឹងកេត** | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |

+ តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ ១ រូប ជាសមាជិក

+ តំណាងនិយោជិតរបស់ **ចំការកៅស៊ូមីមុត** ១ រូប ជាសមាជិកស្វ័យប្រវត្តិ

មាត្រា ៩ ._ -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត**ចំការកៅស៊ូមីមុត** ។

មាត្រា ១០ ._ ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម **ចំការកៅស៊ូមីមុត** ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ចំការកៅស៊ូមីមុត** ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ **ចំការកៅស៊ូមីមុត** ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល **ចំការកៅស៊ូមីមុត** ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និង បែបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ **ចំការកៅស៊ូមីមុត** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

មាត្រា ១១ ._ -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាយក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេការប្រជុំត្រូវលើទៅ ១៥ថ្ងៃក្រោយទៀតដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។

-សេចក្ដីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២._ សេចក្ដីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក **ចំការកៅស៊ូចំការគេន** ។

មាត្រា ១៣._ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ **ចំការកៅស៊ូចំការគេន** និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ ៖

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមតំណាក់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ចំការកៅស៊ូចឹបគេត** ។

២-ទទួលដឹកនាំ **ចំការកៅស៊ូចឹបគេត** លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ **ចំការកៅស៊ូចឹបគេត** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រាបណ្ដាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ចំការកៅស៊ូចឹបគេត** ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្រមតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ **ចំការកៅស៊ូចឹបគេត** ចំពោះមុខតុលាការ និងសាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ឥវ៉ាការពារក្ដីឲ្យ **ចំការកៅស៊ូចឹបគេត** និងការប្ដឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៥ ._** លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៦ ._** ការចុះ និង ការអនុវត្តន៍កិច្ចសន្យាដោយ **ចំការកៅស៊ូចឹបគេត** ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៧ ._** **ចំការកៅស៊ូចឹបគេត** កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្ដើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកត/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-ហោភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ **ចំការកៅស៊ូមីមត** ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់អំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូមីមត** ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ **ចំការកៅស៊ូមីមត** ។

៣- ការប៉ាន់ស្មានថ្លៃទិញ លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ **ចំការកៅស៊ូមីមត** ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូមីមត** ។

**មាត្រា ២០ .**_ ធនធាននៃ **ចំការកៅស៊ូមីងគេត** ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **ចំការកៅស៊ូមីងគេត** ។

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ **ចំការកៅស៊ូមីងគេត** ។

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

**មាត្រា ២១ .**_ ចំណាយនៃ **ចំការកៅស៊ូមីងគេត** រួមមាន :

+ ចំណាយប្រក្រតីសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

**មាត្រា ២២ .**_ **ចំការកៅស៊ូមីងគេត** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា ២៣.**_ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល **ចំការកៅស៊ូមីងគេត** ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ **ចំការកៅស៊ូមីងគេត** មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

**មាត្រា ២៤ .**_ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៥

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៥.**_ រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ចំការកៅស៊ូមីងគេត** ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ **ចំការកៅស៊ូមីងគេត**
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

**មាត្រា ២៦ .**_ ត្រូវបានដាក់ឲ្យនៅអម **ចំការកៅស៊ូមីងគេត** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**ជំពូក ៥**

**អវសានបញ្ញត្តិ**

**មាត្រា ២៧ .**_ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
**ឈា សុខ**

★★★

**អនុក្រឹត្យលេខ ១៨ អនក្រ.បក**

**ស្តីពីការបង្កើត ចំការកៅស៊ូចំការអណ្តូង**

**ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

## សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១.-** ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូងឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូចំការអណ្តូង** សរសេរកាត់ "ច ក ច អ" ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូចំការអណ្តូង** មានទីស្នាក់ការស្ថិតនៅឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម ។
- **ចំការកៅស៊ូចំការអណ្តូង** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

**មាត្រា ២ ._ ចំការកៅស៊ូចំការអណ្តូង** មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ **ចំការកៅស៊ូចំការអណ្តូង** មានភារកិច្ច និង កាតព្វកិច្ចដូចខាងក្រោម ÷

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសម្ភិធិ ការរៀបចំ ការលើកដាក់ ការផ្លាស់ប្តូរ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម-ផលិតកម្ម ។
- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូឯកជន ។
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិស្ថាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធនឹងកម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តទៅរបស់សហគ្រាស ។

**មាត្រា ៣ ._** ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **ចំការកៅស៊ូចំការអណ្តូង** ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការ ដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ **ចំការកៅស៊ូចំការអណ្តូង** ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់សកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាង ណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង្ស និងមានការរីកចំរើន ។

**មាត្រា ៤ ._ ចំការកៅស៊ូចំការអណ្តូង** ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ÷

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត **ចំការកៅស៊ូចំការអណ្តូង**

៣-លក្ខន្តិកៈ **ចំការកៅស៊ូចំការអណ្តូង**

៥-ច្បាប់ និងបទបញ្ញត្តពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

**មាត្រា ៥ ._** **ចំការកៅស៊ូចំការអណ្តូង** ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ៦ ._** ដើមទុនដំបូងនៃ **ចំការកៅស៊ូចំការអណ្តូង** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន **ចំការកៅស៊ូចំការអណ្តូង** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៧._** បុគ្គលិករបស់ **ចំការកៅស៊ូចំការអណ្តូង** ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូង ។

បុគ្គលិករបស់ **ចំការកៅស៊ូចំការអណ្តូង** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២

## ការដឹកនាំនិងគ្រប់គ្រង

**មាត្រា ៨ ._** **ចំការកៅស៊ូចំការអណ្តូង** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក **ចំការកៅស៊ូចំការអណ្តូង** | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |
| + តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ | ១ រូប | ជាសមាជិក |
| + តំណាងនិយោជិតរបស់ **ចំការកៅស៊ូចំការអណ្តូង** | ១ រូប | ជាសមាជិកស្វ័យប្រវត្តិ |

**មាត្រា ៩._** -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍

ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត **ចំការកៅស៊ូចំការអណ្តូង ។**

មាត្រា ១០ .- ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម **ចំការកៅស៊ូចំការអណ្តូង** ក្នុងការរៀបចំពាំខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ចំការកៅស៊ូចំការអណ្តូង ។**

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ **ចំការកៅស៊ូចំការអណ្តូង** ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល **ចំការកៅស៊ូចំការអណ្តូង** ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ **ចំការកៅស៊ូចំការអណ្តូង** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

មាត្រា ១១ ._ -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេអង្គប្រជុំត្រូវពន្យាទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហារបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។

-សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការបែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២._ សេចក្តីសម្រេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរយៈ ១៥ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលត្រូវជ្រើសរើសដោយប្រធានអគ្គនាយក ចំការកៅស៊ូចំការលេខ ។

មាត្រា ១៣ ._ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ចំការកៅស៊ូចំការលេខ និងត្រូវបានតែងតាំង សំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ :

១-រៀបចំឯកសារទាំងឡាយ

ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្ដីសំរេច របស់ក្រុមប្រឹក្សាភិបាល ។ តាមដំណាក់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ចំការកៅស៊ូចំការអណ្ដូង** ។

២-ទទួលដឹកនាំ **ចំការកៅស៊ូចំការអណ្ដូង** លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និង ហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ **ចំការកៅស៊ូចំការអណ្ដូង** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រា បណ្ដាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ចំការកៅស៊ូចំការអណ្ដូង** ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ **ចំការកៅស៊ូចំការអណ្ដូង** ចំពោះមុខតុលាការ និងសាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ឥវ៉ាការពារក្ដីឲ្យ **ចំការកៅស៊ូចំការអណ្ដូង** និងការប្ដឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៥ .-** លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមដំណើររបស់ក្រុម ប្រឹក្សាភិបាល ។

**មាត្រា ១៦ .-** ការចុះ និងការអនុវត្តន៍កិច្ចសន្យាដោយ **ចំការកៅស៊ូចំការអណ្ដូង** ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៧ .- ចំការកៅស៊ូចំការអណ្ដូង** កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញត្តគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្ដើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ **ចំការកៅស៊ូចំការអណ្តូង** ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូចំការអណ្តូង** ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ **ចំការកៅស៊ូចំការអណ្តូង** ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ **ចំការកៅស៊ូចំការអណ្តូង** ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូចំការអណ្តូង** ។

**មាត្រា ២០ .**_ ធនធាននៃ **ចំការកៅស៊ូចំការអណ្តូង** ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **ចំការកៅស៊ូចំការអណ្តូង** ។

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ **ចំការកៅស៊ូចំការអណ្តូង** ។

+ ប្រាក់ដែលបានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

**មាត្រា ២១ .**_ ចំណាយនៃ **ចំការកៅស៊ូចំការអណ្តូង** រួមមាន :

+ ចំណាយប្រព្រឹត្តិសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

**មាត្រា ២២ .**_ **ចំការកៅស៊ូចំការអណ្តូង** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា ២៣ :** ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល **ចំការកៅស៊ូចំការអណ្តូង** ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ **ចំការកៅស៊ូចំការអណ្តូង** មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

**មាត្រា ២៤ .**_ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៥ .**_ រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ចំការកៅស៊ូចំការអណ្តូង** ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល

- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)

- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ **ចំការកៅស៊ូចំការអណ្តូង**
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

មាត្រា ២៦ ._ ត្រូវបានដាក់ឲ្យនៅអម **ចំការកៅស៊ូចំការអណ្តូង** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំង ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

មាត្រា ២៧ ._ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៨ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

| | |
|---|---|
| ទេសរដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ហត្ថលេខា | ហត្ថលេខា |
| **គាត ឈន់** | **ឈា សុខ** |

★★★

**អនុក្រឹត្យលេខ ១៩ អនក្រ.បក**

**ស្តីពីការបង្កើត ចំការកៅស៊ូស្នួល**

**ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរូមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

**សំរេច**

**ជំពូក ១**

**បទបញ្ញត្តិទូទៅ**

**មាត្រា ១.**_ ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូស្នួលឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូស្នួល**

សរសេរកាត់ "ច ក ស" ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូស្នួល** មានទីស្នាក់ការស្ថិតនៅឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ
- **ចំការកៅស៊ូស្នួល** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ

**មាត្រា ២ ._** **ចំការកៅស៊ូស្នួល** មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ **ចំការកៅស៊ូស្នួល** មានភារកិច្ច និង កាតព្វកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការលើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម-ផលិតកម្ម ។
- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្ដីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

**មាត្រា ៣ ._** ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **ចំការកៅស៊ូស្នួល** ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកប កិច្ចការដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ **ចំការកៅស៊ូស្នួល** ត្រូវទទួលស្វ័យភាពយ៉ាង ធំទូលាយ

ដើម្បីពីកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

មាត្រា ៤ ._ **ចំការកៅស៊ូស្នួល** ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ :

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត **ចំការកៅស៊ូស្នួល**

៣-លក្ខន្តិកៈ **ចំការកៅស៊ូស្នួល**

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

មាត្រា ៥ ._ **ចំការកៅស៊ូស្នួល** ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

មាត្រា ៦ ._ ដើមទុនដំបូងនៃ **ចំការកៅស៊ូស្នួល** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន **ចំការកៅស៊ូស្នួល** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៧._ បុគ្គលិករបស់ **ចំការកៅស៊ូស្នួល** ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុម-ហ៊ុនចំការកៅស៊ូស្នួល ។

បុគ្គលិករបស់ **ចំការកៅស៊ូស្នួល** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២

## ការដឹកនាំនិងគ្រប់គ្រង

មាត្រា ៨ ._ **ចំការកៅស៊ូស្នួល** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| + ប្រធានអគ្គនាយក **ចំការកៅស៊ូស្នួល** | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តក្រចេះ ឬតំណាង | ១ រូប | ជាសមាជិក |

+ តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ ១ រូប ជាសមាជិក

+ តំណាងនិយោជិតរបស់ **ចំការកៅស៊ូស្នួល** ១ រូប ជាសមាជិកស្ម័យប្រវត្តិ

**មាត្រា ៩.-** សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។

- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត **ចំការកៅស៊ូស្នួល**

**មាត្រា ១០ .-** ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម **ចំការកៅស៊ូស្នួល** ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ចំការកៅស៊ូស្នួល** ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ **ចំការកៅស៊ូស្នួល** ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្សប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល **ចំការកៅស៊ូស្នួល** ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះ ដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ **ចំការកៅស៊ូស្នួល** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

មាត្រា ១១.- ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំង ឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់ រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើទៅ ១៥ថ្ងៃក្រោយទៀតដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំបើកក្រោយនេះពុំបាច់តាមទារកូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២.- សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក **ចំការកៅស៊ូស្នួល** ។

មាត្រា ១៣ .- ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ **ចំការកៅស៊ូស្នួល** និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

មាត្រា ១៤.- ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ :

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមកំណត់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ **ចំការកៅស៊ូស្នួល** ។

២-ទទួលដឹកនាំ **ចំការកៅស៊ូស្នួល** លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ **ចំការកៅស៊ូស្នួល** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រា បណ្ដាភ្នាក់ងារឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ចំការកៅស៊ូស្នួល** ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្រេមតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ **ចំការកៅស៊ូស្នួល** ចំពោះមុខតុលាការ និងសាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ឥវ៉ាការពារក្ដីឲ្យ **ចំការកៅស៊ូស្នួល** និងការប្ដឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៥ .-** លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៦ ._** ការចុះ និងការអនុវត្តន៍កិច្ចសន្យាដោយ **ចំការកៅស៊ូស្នួល** ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៧._** **ចំការកៅស៊ូស្នួល** កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្ដើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-គណនេយ្យករ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) លើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-គណនេយ្យករ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឃើញឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជាក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ ចំការកៅស៊ូស្នួល ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ចំការកៅស៊ូស្នួល ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ចំការកៅស៊ូស្នួល ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ ចំការកៅស៊ូស្នួល ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ ចំការកៅស៊ូស្នួល ។

មាត្រា ២០ ._ ធនធាននៃ ចំការកៅស៊ូស្នួល ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (គណនេយ្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **ចំការកៅស៊ូស្នួល ។**

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ **ចំការកៅស៊ូស្នួល ។**

+ ប្រាក់ដែលបានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

**មាត្រា ២១ ._** ចំណាយនៃ **ចំការកៅស៊ូស្នួល** រួមមាន :

+ ចំណាយប្រព្រឹត្តិសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

**មាត្រា ២២ ._** **ចំការកៅស៊ូស្នួល** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់ តំរូវការរបស់ខ្លួន ។

**មាត្រា ២៣._** ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល **ចំការកៅស៊ូស្នួល** ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ **ចំការកៅស៊ូស្នួល** មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះ ឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

**មាត្រា ២៤ ._** រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៥ ._** រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ចំការកៅស៊ូស្នួល** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ **ចំការកៅស៊ូស្នួល**
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

**មាត្រា ២៦ ._** ត្រូវបានដាក់ឲ្យនៅអមុ **ចំការកៅស៊ូស្នួល** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំង ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ

ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**ជំពូក ៥**

**អវសានបញ្ញត្តិ**

**មាត្រា ២៧ .-** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរខេត្តក្រចេះ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ហត្ថលេខា

**ឈា សុខ**

★★★

**អនុក្រឹត្យលេខ ៦៦ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/០៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

សម្រេច

**មាត្រា ១ .-** តែងតាំងលោក ឈៀង ទណ្ឌដារ៉ុន ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងព័ត៌មាន ។

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តន៍តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៦៧ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៩អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

**មាត្រា ១ .-** តែងតាំងលោក កែវ ឡុង បច្ចុប្បន្នជាអនុប្រធាននាយកដ្ឋានទទួលរួមនាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តន៍អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៦៨ អនក្រ.តត
## ស្តីពីការដាក់មន្ត្រីរាជការឲ្យចូលនិវត្តន៍

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ ._ ដាក់ឲ្យចូលនិវត្តន៍អស់លោកអភិបាលរងខេត្ត-ក្រុង ដូចមានរាយនាមខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| ១- លោក អ៊ុច ឡឿន | អភិបាលរងទី១ | ខេត្ត | កំពង់ស្ពឺ |
| ២- លោក តិត រាម | អភិបាលរងទី១ | ខេត្ត | កំពត |
| ៣- លោក អ៊ុំ ស៊ឹម | អភិបាលរងទី២ | ខេត្ត | កំពង់ស្ពឺ |
| ៤- លោក គួច សារ៉ន | អភិបាលរងទី២ | ខេត្ត | ស្វាយរៀង |
| ៥- លោក ស៊ុំ អ៊ាន | អភិបាលរងទី២ | ខេត្ត | ព្រះវិហារ |
| ៦- លោក ជា វណ្ណាលន | អភិបាលរងទី៣ | ខេត្ត | តាកែវ |

៧- លោក សា គីម អភិបាលរងទី៣ ខេត្ត រតនគិរី

៨- លោក នេត ឃួន អភិបាលរងទី៣ ក្រុង កែប

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តនូវអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៦៩ អនក្រ.តត

## ស្តីពីការតែងតាំងអភិបាលរង ខេត្ត-ក្រុង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-** តែងតាំងអស់លោក លោកស្រី ជាអភិបាលរង ខេត្ត-ក្រុង ដូចមានរាយនាមខាងក្រោម ៖

១- លោក **ណាំ នុំ** ជាអភិបាលរងទី១ ខេត្ត សៀមរាប

២- លោក **ឆាយ សារ៉េត** ជាអភិបាលរងទី១ ខេត្ត ព្រៃវែង

៣- លោក **យឹម មុំ** ជាអភិបាលរងទី១ ខេត្ត កណ្តាល

៤- លោក **យឹម សុខុម** ជាអភិបាលរងទី១ ខេត្ត កំពង់ស្ពឺ

៥- លោក **ឈឹម ជួន** ជាអភិបាលរងទី១ ខេត្ត កំពត

| | | | | | |
|---|---|---|---|---|---|
| ៦- | លោក | ម៉ៅ នឹម | ជាអភិបាលរងទី១ | ខេត្ត | ឧត្តរមានជ័យ |
| ៧- | លោក | មាស ថន | ជាអភិបាលរងទី១ | ខេត្ត | មណ្ឌលគិរី |
| ៨- | លោក | ឈុន ស៊ីរុន | ជាអភិបាលរងទី១ | ក្រុង | ព្រះសីហនុ |
| ៩- | លោក | អាន ហេ | ជាអភិបាលរងទី១ | ក្រុង | កែប |
| ១០- | លោក | អៀង ខុន | ជាអភិបាលរងទី១ | ក្រុង | ប៉ៃលិន |
| ១១- | លោក | អ៊ុំ សារិទ្ធ | ជាអភិបាលរងទី១ | ខេត្ត | ស្ទឹងត្រែង |
| ១២- | លោក | អន ស៊ុំ | ជាអភិបាលរងទី១ | ខេត្ត | បន្ទាយមានជ័យ |
| ១៣- | លោក | ឈឹម ឆាម | ជាអភិបាលរងទី១ | ខេត្ត | ស្វាយរៀង |
| ១៤- | លោក | ថាវ គីមឡុង | ជាអភិបាលរងទី១ | ខេត្ត | កំពង់ចាម |
| ១៥- | លោក | គី សារ៉ា | ជាអភិបាលរងទី១ | ខេត្ត | កំពង់ធំ |
| ១៦- | លោក | ហែម សារឧទ្យ | ជាអភិបាលរងទី១ | ខេត្ត | កំពង់ធំ |
| ១៧- | លោក | យ៉ឹម សិលា | ជាអភិបាលរងទី១ | ខេត្ត | ពោធិសាត់ |
| ១៨- | លោក | ស៊ឹម សុន | ជាអភិបាលរងទី១ | ខេត្ត | ក្រចេះ |
| ១៩- | លោក | ប៉ុល សាន្ត | ជាអភិបាលរងទី១ | ខេត្ត | តាកែវ |
| ២០- | លោក | សាន់ ឃៀម | ជាអភិបាលរងទី១ | ខេត្ត | បាត់ដំបង |
| ២១- | លោក | សាយ ហាក់ | ជាអភិបាលរងទី២ | ខេត្ត | កោះកុង |
| ២២- | លោក | ម៉ុន សុបណ្ណ | ជាអភិបាលរងទី១ | ខេត្ត | ព្រះវិហារ |
| ២៣- | លោក | ទ័ន ឈុនលី | ជាអភិបាលរងទី១ | ខេត្ត | រតនគិរី |
| ២៤- | លោក | ប៉ា សុជាតិវង្ស | ជាអភិបាលរងទី២ | ខេត្ត | បាត់ដំបង |
| ២៥- | លោក | ម៉ៅ គីរុណ | ជាអភិបាលរងទី២ | ខេត្ត | កំពង់ចាម |
| ២៦- | លោក | សោម សុផាត | ជាអភិបាលរងទី២ | ខេត្ត | កំពង់ធំ |
| ២៧- | លោក | ឆួច ម៉ារីម | ជាអភិបាលរងទី២ | ខេត្ត | កំពង់ឆ្នាំង |
| ២៨- | លោក | ខូយ សុខា | ជាអភិបាលរងទី២ | ខេត្ត | ពោធិសាត់ |
| ២៩- | លោក | ខាំ គឿន | ជាអភិបាលរងទី២ | ខេត្ត | ក្រចេះ |
| ៣០- | លោក | ខួន ម៉ែន | ជាអភិបាលរងទី២ | ខេត្ត | ស្វាយរៀង |
| ៣១- | លោក | ឡុង សុបណ្ណ | ជាអភិបាលរងទី២ | ខេត្ត | ព្រះវិហារ |
| ៣២- | លោក | ម៉ុន ហ្វូមអួនម៉ានី | ជាអភិបាលរងទី២ | ខេត្ត | រតនគិរី |
| ៣៣- | លោក | ឡាយ សុខា | ជាអភិបាលរងទី២ | ខេត្ត | តាកែវ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៤- | លោក | អ៊ុំ | ទ៉ន | ជាអភិបាលរងទី២ | ខេត្ត | កោះកុង |
| ៣៥- | លោក | ញិក | គិមឈុន | ជាអភិបាលរងទី២ | ខេត្ត | បន្ទាយមានជ័យ |
| ៣៦- | លោកស្រី | ផេង | គីម | ជាអភិបាលរងទី២ | ខេត្ត | ស្ទឹងត្រែង |
| ៣៧- | លោក | ស៊ុយ | សាន | ជាអភិបាលរងទី២ | ខេត្ត | សៀមរាប |
| ៣៨- | លោក | មឿង | កែល | ជាអភិបាលរងទី២ | ខេត្ត | ឧត្តរមានជ័យ |
| ៣៩- | លោក | ឡាច | ស៊ីមអ៊ួន | ជាអភិបាលរងទី២ | ខេត្ត | ព្រៃវែង |
| ៤០- | លោក | រុំ | តិក្ខមុនី | ជាអភិបាលរងទី២ | ខេត្ត | កណ្ដាល |
| ៤១- | លោក | អោគ | សំអេន | ជាអភិបាលរងទី២ | ខេត្ត | កំពង់ស្ពឺ |
| ៤២- | លោក | ម៉េង | សួន | ជាអភិបាលរងទី២ | ខេត្ត | កំពត |
| ៤៣- | លោក | ច័ន្ទ | សំអាន | ជាអភិបាលរងទី២ | ក្រុង | កែប |
| ៤៤- | លោក | ពុត | ចន្ថារិទ្ធ | ជាអភិបាលរងទី២ | ក្រុង | ព្រះសីហនុ |
| ៤៥- | លោក | កើត | សុធា | ជាអភិបាលរងទី២ | ក្រុង | ប៉ៃលិន |
| ៤៦- | លោក | ប៉ាល់ | សំអឿន | ជាអភិបាលរងទី៣ | ខេត្ត | បន្ទាយមានជ័យ |
| ៤៧- | លោក | ប៉ាវ | ហមផាន | ជាអភិបាលរងទី៣ | ខេត្ត | ស្ទឹងត្រែង |
| ៤៨- | លោក | ប៊ិច | សុខិន | ជាអភិបាលរងទី៣ | ខេត្ត | សៀមរាប |
| ៤៩- | លោក | យឹម | ធិន | ជាអភិបាលរងទី៣ | ខេត្ត | ឧត្តរមានជ័យ |
| ៥០- | លោក | ញ៉ោ | វ៉ាងចាន់ | ជាអភិបាលរងទី៣ | ខេត្ត | មណ្ឌលគិរី |
| ៥១- | លោក | ស៊ុន | ហេង | ជាអភិបាលរងទី៣ | ខេត្ត | ព្រៃវែង |
| ៥២- | លោក | ម៉ក់ | សំអឿន | ជាអភិបាលរងទី៣ | ខេត្ត | កណ្ដាល |
| ៥៣- | លោក | កុង | ហ៊ាង | ជាអភិបាលរងទី៣ | ខេត្ត | កំពង់ស្ពឺ |
| ៥៤- | លោក | ឈិត | សុខុន | ជាអភិបាលរងទី៣ | ខេត្ត | កំពត |
| ៥៥- | លោក | សំ | សារីន | ជាអភិបាលរងទី៣ | ក្រុង | កែប |
| ៥៦- | លោក | ស្បោង | សារ៉ាត | ជាអភិបាលរងទី៣ | ក្រុង | ព្រះសីហនុ |
| ៥៧- | លោក | ប្រាក់ | ឡឿន | ជាអភិបាលរងទី៣ | ខេត្ត | បាត់ដំបង |
| ៥៨- | លោក | សៀក | ជីវឡេង | ជាអភិបាលរងទី៣ | ខេត្ត | កំពង់ចាម |
| ៥៩- | លោក | គង់ | ប៊ុនថន | ជាអភិបាលរងទី៣ | ខេត្ត | កំពង់ធំ |
| ៦០- | លោក | ធី | គឹមតុក | ជាអភិបាលរងទី៣ | ខេត្ត | ពោធិសាត់ |
| ៦១- | លោក | សុប | វ៉ា | ជាអភិបាលរងទី៣ | ខេត្ត | កំពង់ឆ្នាំង |

| | | | | | |
|---|---|---|---|---|---|
| ៦២- លោក | សុខ | វ៉ាហ្វ៊ីរ | ជាអភិបាលរងទី៣ | ខេត្ត | ក្រចេះ |
| ៦៣- លោក | ស្លា | ប្រយុទ្ធ | ជាអភិបាលរងទី៣ | ខេត្ត | ស្វាយរៀង |
| ៦៤- លោក | គាន់ | ទុឡឺ | ជាអភិបាលរងទី៣ | ខេត្ត | ព្រះវិហារ |
| ៦៥- លោក | ឆន | ស៊ីម | ជាអភិបាលរងទី៣ | ខេត្ត | រតនគិរី |
| ៦៦- លោក | អ៊ុយ | ខេមរា | ជាអភិបាលរងទី៣ | ខេត្ត | តាកែវ |
| ៦៧- លោក | ពេជ | ហន | ជាអភិបាលរងទី៣ | ខេត្ត | កោះកុង |

**មាត្រា ២ ._** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៧០ អនក្រ.តត

## ស្តីពីការផ្លាស់ប្តូរភារកិច្ចរបស់មន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ ._ ត្រូវបានផ្លាស់ប្តូរអស់លោក អភិបាលរង ខេត្ត-ក្រុង ឲ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារតាមដានសភាពការណ៍ខេត្ត-ក្រុង ដោយរក្សាឋានៈដដែល ដូចមាននាមខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១- លោក | គង់ ស៊ាន | អភិបាលរងទី១ | ខេត្ត | កំពង់ចាម |
| ២- លោក | ផ្លូង គឹមឆុន | អភិបាលរងទី១ | ខេត្ត | បាត់ដំបង |
| ៣- លោក | ឡាច សុគ៌ | អភិបាលរងទី១ | ខេត្ត | កំពង់ឆ្នាំង |
| ៤- លោក | ជិន សុធា | អភិបាលរងទី១ | ខេត្ត | កំពង់ធំ |
| ៥- លោក | ទ៊ែន សុខួយ | អភិបាលរងទី១ | ខេត្ត | ក្រចេះ |
| ៦- លោក | អ៊ិច សារូ | អភិបាលរងទី១ | ខេត្ត | មណ្ឌលគិរី |
| ៧- លោក | ខួយ ឃុនហ៊ួរ | អភិបាលរងទី១ | ខេត្ត | ព្រះវិហារ |
| ៨- លោក | ស្រី មណ្ឌល | អភិបាលរងទី១ | ខេត្ត | ស្វាយរៀង |
| ៩- លោក | ប្រាក់ សាទុធ | អភិបាលរងទី២ | ខេត្ត | កណ្តាល |
| ១០- លោក | ជ័យ សាយឿន | អភិបាលរងទី២ | ខេត្ត | ព្រៃវែង |
| ១១- លោក | ហ៊ីង សារិន្ទ | អភិបាលរងទី២ | ក្រុង | ព្រះសីហនុ |
| ១២- លោក | សួន សារិទ្ធិ | អភិបាលរងទី២ | ខេត្ត | កំពត |
| ១៣- លោក | ជី ហួត | អភិបាលរងទី២ | ក្រុង | កែប |
| ១៤- លោក | សូ ណាត | អភិបាលរងទី៣ | ខេត្ត | កំពង់ចាម |
| ១៥- លោក | ការ លាន | អភិបាលរងទី៣ | ខេត្ត | ពោធិសាត់ |
| ១៦- លោក | ឡេង លឿង | អភិបាលរងទី៣ | ខេត្ត | កំពង់ឆ្នាំង |
| ១៧- លោក | អ៊ុង ម៉ុន | អភិបាលរងទី៣ | ខេត្ត | បន្ទាយមានជ័យ |
| ១៨- លោក | ជាញ់ អាង | អភិបាលរងទី៣ | ខេត្ត | ក្រចេះ |
| ១៩- លោក | កុយ សារឹម | អភិបាលរងទី៣ | ខេត្ត | ស្ទឹងត្រែង |

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៧១ អនក្រ.តត

## ស្ដីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ ._ តែងតាំងលោក **សត់ សេដ្ឋា** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ។

មាត្រា ២ ._ ផ្ទេរ និង តែងតាំងលោក **ហួយ គីមឡុង** ពីប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុក្រសួងទេសចរណ៍ មកជាប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ ។

មាត្រា ៣ ._ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ៧២ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៩អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធសមាសភាព និងតួនាទីរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- យោងតាមសំណើរបស់អនុប្រធានក្រុមប្រឹក្សាស្តារ វិស័យកសិកម្ម និងជនបទ

**សំរេច**

**មាត្រា ១ .**_ ត្រូវបានតែងតាំងជូន

១- លោក **សុខ ស៊ីផាន្ន** ជាប្រធានផ្នែករដ្ឋបាល មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២- លោក **ណី សុឃីម** ជាប្រធានផ្នែកអាជីវកម្មព្រៃឈើ និងជលផល មានឋានៈស្មើ ប្រធាននាយកដ្ឋាន

**មាត្រា ២ .**_ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងពាក់ព័ន្ធ និងឯកឧត្តម អស់លោក លោកស្រី ដែលមានរាយនាមក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យលេខ ៧៣ អនក្រ.តត
## ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារ និង តម្លើងឋានន្តរសក្តិ
## នាយទាហាននៃកងយោធពលខេមរភូមិន្ទ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ

## សម្រេច

មាត្រា ១ ._ ត្រូវបានតែងតាំងផ្លាស់ប្តូរមុខងារ និង តម្លើងឋានន្តរសក្តិនាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ ជុំ សាគុណ អត្តលេខ ០០០៩១២ បច្ចុប្បន្នជា មេបញ្ជាការតំបន់ប្រតិបត្តិសឹករងកំពង់ចាម និងជាវរសេនីយ៍ឯក នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ គ្រប់ក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ១៧ សសរ.
### ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែន
### កម្ពុជា-ថៃ

***

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្មកិច្ចការព្រំដែន ចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសកិច្ចការព្រំដែនចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- យោងតាមតំរូវការចាំបាច់

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-ថៃ ដែលមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម **វ៉ា គឹមហុង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ុល សារឿន** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ទីប្រឹក្សា

៣- ឯកឧត្តម ឡុង ទិសាឡោ អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤- ឯកឧត្តម ម៉ុន សម អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម អភិបាលខេត្ត ព្រះវិហារ សមាជិក

៦- ឯកឧត្តម អភិបាលខេត្ត ឧត្តរមានជ័យ សមាជិក

៧- ឯកឧត្តម អភិបាលខេត្ត បន្ទាយមានជ័យ សមាជិក

៨- ឯកឧត្តម អភិបាលខេត្ត បាត់ដំបង សមាជិក

៩- ឯកឧត្តម អភិបាលខេត្ត ពោធិសាត់ សមាជិក

១០- ឯកឧត្តម អភិបាលខេត្ត កោះកុង សមាជិក

១១- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ប៉ៃលិន សមាជិក

១២- លោក ហួន សាខ៊ាង ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងនគរូនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍

១៣- លោកឧត្តមសេនីយ៍ទោ ឆាម៉ន មេបញ្ជាការយោធភូមិភាគ៤ សមាជិក

១៤- លោកឧត្តមសេនីយ៍ទោ ម៉ុន សេង មេបញ្ជាការយោធភូមិភាគ៥ សមាជិក

១៥- លោកឧត្តមនាវីទោ អ៊ុំ សំខាន់ មេបញ្ជាការកងទ័ពជើងទឹក សមាជិក

១៦- លោកឧត្តមសេនីយ៍ត្រី ចាន់ អ៊ាន ប្រធាននាយកដ្ឋានព្រំដែនគោក ក្រសួងមហាផ្ទៃ សមាជិក

១៧- លោកឧត្តមសេនីយ៍ទោ ឈុំ សុជាតិ ប្រធាននាយកដ្ឋានការពារព្រំដែន អគ្គសេនាធិការ សមាជិក

១៨- លោក រស់ គង់ ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៩- លោក ឡុង ផុល ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២០- លោក អ៊ុក សុម៉ារីម ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ សមាជិក

២១- លោកឧត្តមសេនីយ៍ត្រី ខេត ចំរើន ប្រធាននាយកដ្ឋានភូមិសាស្ត្រក្រសួងការពារជាតិ សមាជិក

២២- លោក ហ៊ី សាគុណ អនុប្រធានទី១ នាយកដ្ឋាននគរបាលព្រំដែនទឹក ក្រសួងមហាផ្ទៃ សមាជិក

២៣- លោក ស៊ា កុសល អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ . សមាជិក

ប្រការ ២ : គណៈកម្មាធិការចំរុះ កិច្ចការព្រំដែនកម្ពុជា-ថៃ មានភារកិច្ច ដូចខាងក្រោម :

ក- ពិនិត្យ និងដោះស្រាយរាល់បញ្ហាទាក់ទង និងការខ័ណ្ឌព្រំដែនសីមា និងបោះបង្គោលព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ ។

ខ- ចរចាជាមួយភាគីថៃ ដើម្បីដោះស្រាយនូវរាល់បញ្ហាទាក់ទងនឹងការខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ ។

គ- រៀបចំសន្និសញ្ញាស្តីពីការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យសំរេច ។

ឃ- ដឹកនាំការងារខ័ណ្ឌព្រំដែនសីមា និងបោះបង្គោលព្រំដែន ។

ង- ដោះស្រាយនូវរាល់បញ្ហា ស្តីពីការអនុវត្តន៍លក្ខន្តិកៈព្រំដែនរវាងកម្ពុជា-ថៃ ។

ច- ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការខ័ណ្ឌព្រំសីមា និងបោះបង្គោលព្រំដែនជាមួយប្រទេសថៃ ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់ការរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ ៣ : ដើម្បីបំពេញការងារខាងលើនេះ គណៈកម្មាធិការចំរុះអាចនឹងបង្កើតក្រុមបច្ចេកទេសសំរាប់ធ្វើជាសេនាធិការ ។

ប្រការ ៤ : គ្រប់សមាជិកនៃគណៈកម្មាធិការ ត្រូវចូលរួមតាមការកោះអញ្ជើញរបស់គណៈកម្មាធិការ។

ប្រការ ៥ : គណៈកម្មាធិការនេះមានទីស្នាក់ការរបស់ខ្លួននៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៩

**សេចក្តីសំរេចលេខ ១៨ សសរ.**

**ស្តីពីការបង្កើតគណៈក ម្មាធិការចំរុះកិច្ចការព្រំដែន**

**កម្ពុជា-ឡាវ**

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្ម កិច្ចការព្រំដែនចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសកិច្ចការព្រំដែនចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- យោងតាមតំរូវការចាំបាច់

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-ឡាវ ដែលមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម**វ៉ា គឹមហុង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ឯកប៉ុល **សារឿន** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ទីប្រឹក្សា

៣- ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤- ឯកឧត្តម **ម៉ុន សម** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម អភិបាលខេត្ត រតនគិរី សមាជិក

៦- ឯកឧត្តម អភិបាលខេត្ត ស្ទឹងត្រែង សមាជិក

៧- ឯកឧត្តម អភិបាលខេត្ត ព្រះវិហារ សមាជិក

៨- លោក **ហួន សារ៉ាវ** ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងនគរូបនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍

៩- លោកឧត្តមសេនីយ៍ទោ **ថៅ គង់** មេបញ្ជាការយោធភូមិភាគ១ សមាជិក

១០-លោកឧត្តមសេនីយ៍ត្រី **ចាន់ អ៊ាន** ប្រធាននាយកដ្ឋានព្រំដែនគោកក្រសួងមហាផ្ទៃ សមាជិក

១១-លោកឧត្តមនាវីទោ **ឈុំ សុជាតិ** ប្រធាននាយកដ្ឋានការពារព្រំដែននៃអគ្គសេនាធិការ សមាជិក

១២-លោក **រស់ គង់** ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៣-លោក **ឡុង ផុល** ប្រធានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៤-លោក **អ៊ុក សូម៉ារីម** ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ សមាជិក

១៥-លោកឧត្តមសេនីយ៍ត្រី **ឆេត ចំរើន** ប្រធាននាយកដ្ឋានភូមិសាស្ត្រក្រសួងការពារជាតិ សមាជិក

១៦-លោក **ស៊ា កុសល** អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

**ប្រការ ២ :** គណៈកម្មាធិការចំរុះ កិច្ចការព្រំដែនកម្ពុជា-ឡាវ មានភារកិច្ច ដូចខាងក្រោម :

ក- ពិនិត្យ និងដោះស្រាយរាល់បញ្ហាទាក់ទង និងការកំណត់ព្រំដែនកម្ពុជា-ឡាវ ។

ខ- ចរចាជាមួយភាគីឡាវ ដើម្បីដោះស្រាយនូវរាល់បញ្ហាទាក់ទងនឹងការកំណត់ព្រំដែនកម្ពុជា-ឡាវ ។

គ- រៀបចំសន្ធិសញ្ញាសកំណត់ព្រំដែន ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

ឃ- ដឹកនាំការងារ ខណ្ឌព្រំដែនសីមា និងបោះបង្គោលព្រំដែន ។

ង- ដោះស្រាយនូវរាល់បញ្ហា ស្តីពីការអនុវត្តន៍លក្ខន្តិកៈព្រំដែនរវាងកម្ពុជា-ឡាវ ។

ច- ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ព្រំដែនជាមួយប្រទេសឡាវ ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់ការរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ ៣ : ដើម្បីបំពេញការងារខាងលើនេះ គណៈកម្មាធិការចំរុះអាចនឹងបង្កើតក្រុមបច្ចេកទេសសំរាប់ធ្វើជាសេនាធិការ ។

ប្រការ ៤ : គ្រប់សមាជិកនៃគណៈកម្មាធិការ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់គណៈកម្មាធិការ ។

ប្រការ ៥ : គណៈកម្មាធិការនេះមានទីស្នាក់ការរបស់ខ្លួននៅទីស្ដីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្ត សេចក្ដីសំរេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៩

## សេចក្ដីសំរេចលេខ ១៩ សសរ.

## ស្ដីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែន កម្ពុជា-វៀតណាម

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្មកិច្ចការព្រំដែន ចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេស កិច្ចការព្រំដែនចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- **យោងតាមតំរូវការចាំបាច់**

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម **វ៉ា គឹមហុង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ុល សារឿន** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ទីប្រឹក្សា

៣- ឯកឧត្តម **ឡុង ទិសាលោ** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤- ឯកឧត្តម **ម៉ុន សម** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម អភិបាលខេត្ត រតនគីរី សមាជិក

៦- ឯកឧត្តម អភិបាលខេត្ត មណ្ឌលគីរី សមាជិក

៧- ឯកឧត្តម អភិបាលខេត្ត ក្រចេះ សមាជិក

៨- ឯកឧត្តម អភិបាលខេត្ត កំពង់ចាម សមាជិក

៩- ឯកឧត្តម អភិបាលខេត្ត ស្វាយរៀង សមាជិក

១០- ឯកឧត្តម អភិបាលខេត្ត ព្រៃវែង សមាជិក

១១- ឯកឧត្តម អភិបាលខេត្ត កណ្តាល សមាជិក

១២- ឯកឧត្តម អភិបាលខេត្ត តាកែវ សមាជិក

១៣- ឯកឧត្តម អភិបាលខេត្ត កំពត សមាជិក

១៤- **លោក ហួន សាទ៉ាង** ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងនគរូបនីយកម្មនិងសំណង់ សមាជិកអចិន្ត្រៃយ៍

១៥- លោកឧត្តមសេនីយ៍ត្រី **ចាន់ ស៊ាន** ប្រធាននាយកដ្ឋានព្រំដែនគោក ក្រសួងមហាផ្ទៃ សមាជិក

១៦- លោកឧត្តមសេនីយ៍ទោ **ឈុំ សុជាតិ** ប្រធាននាយកដ្ឋានការពារព្រំដែននៃអគ្គសេនាធិការ សមាជិក

១៧- លោកឧត្តមសេនីយ៍ទោ **ជឿន សុវណ្ណថា** មេបញ្ជាការយោធភូមិភាគ ២ សមាជិក

១៨- លោកឧត្តមនាវីទោ **អ៊ុី សំខាន់** មេបញ្ជាការកងទ័ពជើងទឹក សមាជិក

១៩- លោក **ស៊ សុខ** ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២០- លោក **ឡុង ឌុល** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២១- លោក **អ៊ុត សុម៉ារឹម** ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ សមាជិក

២២- លោកឧត្តមសេនីយ៍ត្រី **ឆេត ចំរើន** ប្រធាននាយកដ្ឋានភូមិសាស្ត្រក្រសួងការពារជាតិ សមាជិក

២៣- លោក **ហ៊ី សារុណ** អនុប្រធានទី១ នាយកដ្ឋាននគរបាលព្រំដែនទឹក ក្រសួងមហាផ្ទៃ សមាជិក

២៤- លោក **ស៊ា កុសល** អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

**ប្រការ ២ :** គណៈកម្មាធិការចំពោះ កិច្ចការព្រំដែនកម្ពុជា-វៀតណាម មានភារកិច្ច ដូចខាងក្រោម :

ក- ពិនិត្យ និងដោះស្រាយរាល់បញ្ហាទាក់ទង និងការកំណត់ព្រំដែនគោក និងសមុទ្រកម្ពុជា-វៀតណាម ។

ខ-ចរចាជាមួយភាគីថៃ ដើម្បីដោះស្រាយនូវរាល់បញ្ហាទាក់ទងនឹងការកំណត់ព្រំដែនគោក និងសមុទ្រកម្ពុជា-វៀតណាមបន្តទៀត ។

គ- រៀបចំសន្ធិសញ្ញាបំពេញបន្ថែមលើការកំណត់ព្រំដែនគោក និងសមុទ្រ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

ឃ- ដឹកនាំការងារខណ្ឌព្រំដែនសីមា និងបោះបង្គោលព្រំដែន ។

ង- ដោះស្រាយនូវរាល់បញ្ហា ស្តីពីការអនុវត្តន៍លក្ខន្តិកៈព្រំដែនរវាងកម្ពុជា-វៀតណាម។

ច- ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ព្រំដែនជាមួយប្រទេសថៃ ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់ការរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ ៣ : ដើម្បីបំពេញការងារខាងលើនេះ គណៈកម្មាធិការចំរុះអាចនឹងបង្កើតក្រុមបច្ចេកទេសសំរាប់ធ្វើជាសេនាធិការ ។

ប្រការ ៤ : គ្រប់សមាជិកនៃគណៈកម្មាធិការ ត្រូវចូលរួមតាមការកោះអញ្ជើញរបស់គណៈកម្មាធិការ។

ប្រការ ៥ : គណៈកម្មាធិការនេះមានទីស្នាក់ការរបស់ខ្លួននៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័ន អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៩

**សេចក្តីសំរេចលេខ ២០ សសរ.**

**ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយបាតុភាព**

**នៅភូមិខ្សាច់ ឃុំកោះសំពៅ ស្រុកពាមជ ខេត្តព្រៃវែង**

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការសំរាប់ដោះស្រាយបាតុភាពនៅភូមិខ្សាច់ ឃុំកោះសំពៅ ស្រុកពាមជ ខេត្តព្រៃវែង ដែលមានសមាសភាព ដូចតទៅ :

១- លោកជំទាវ លី វុចឡេង រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ប្រធាន
២- ឯកឧត្តមឧត្តមសេនីយ៍ត្រី សោ សុខា មេបញ្ជាការរងនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
៣- ឯកឧត្តម ម៉ុល លឹម អគ្គាធិការរងក្រសួងមហាផ្ទៃ សមាជិក
៤- លោក យ៉ា លេងហាក់ ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៥- តំណាងអាជ្ញាធរខេត្តព្រៃវែង សមាជិក
៦- តំណាងអាជ្ញាធរស្រុកពាមជ សមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

ចុះស្រាវជ្រាវ និងលើកវិធានការដោះស្រាយឲ្យមានប្រសិទ្ធភាព នូវរាល់បាតុភាពដែលកើតមានឡើងនៅភូមិខ្សាច់ ឃុំកោះសំពៅ ស្រុកពាមជ ខេត្តព្រៃវែង ។

ធ្វើរបាយការណ៍អំពីវិធានការដោះស្រាយ និងលទ្ធផលនៃការងារខាងលើ ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះ មានប្រសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ សំរាប់សំរួលការងារ ។

**ប្រការ ៤:** បទបញ្ញត្តិទាំងឡាយណាផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងលោកជំទាវ ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

# សេចក្តីសំរេចលេខ ២១ សសរ.

## ស្តីពីការបង្កើតគណៈកម្មការចំរុះដោះស្រាយ

## បញ្ហាជនអានាថា ក្នុងរាជធានីភ្នំពេញ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីសំរេចលេខ ២៧សសរ. ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការចំរុះដោះស្រាយបញ្ហាជនអនាថាក្នុងរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះដោះស្រាយបញ្ហាជនអានាថា ក្នុងរាជធានីភ្នំពេញ ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ប្រធាន |
| ២- ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ | អនុប្រធាន |
| ៤- លោកតំណាងក្រសួងសុខាភិបាល | សមាជិក |
| ៥- លោក តំណាងក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ៦- លោក តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៧- លោក តំណាងក្រសួងកិច្ច ការនារី និងអតីតយុទ្ធជន | សមាជិក |
| ៨- លោក តំណាងក្រសួងពត៌មាន | សមាជិក |
| ៩- លោក តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |

១០- លោក ជំទាវប្រធានគណៈកម្មាធិការសមាគមកាកបាទក្រហមកម្ពុជា សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ប្រមូលជនអានាថាទាំងអស់ ក្នុងរាជធានីភ្នំពេញ ដើម្បីបញ្ជូនឲ្យទៅរស់នៅតាមបណ្តាខេត្តរបស់ខ្លួនវិញ ។

ក្នុងរយៈពេលប្រមូលផ្តុំ ត្រូវដោះស្រាយរកជំរកស្នាក់នៅបណ្តោះអាសន្ន ឧបត្ថម្ភស្បៀងអាហារ ព្យាបាលជម្ងឺ ធ្វើការអប់រំ ណែនាំឲ្យបានល្អ និងសម្រួល ព្រមទាំងទទួលបន្ទុកបើមធ្យោបាយដឹកជញ្ជូនជនទាំងនោះឲ្យបានដល់មូលដ្ឋាន ដែលជាគោលដៅរស់នៅអចិន្ត្រៃយ៍របស់គេ ។

ប្រការ ៣ : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការ នេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទា ។

ប្រការ ៤ : គណៈកម្មការនេះមានសិទ្ធិបង្កើតគណៈកម្មការអចិន្ត្រៃយ៍ ដើម្បីអនុវត្តជាប់ជាប្រចាំសំដៅទប់ស្កាត់ជនអនាថា ក្នុងទីក្រុងមិនឲ្យកើតមានឡើងវិញ ។

ប្រការ ៥ : សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រី ក្រសួងសុខាភិបាល រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ រដ្ឋមន្ត្រីក្រសួង អភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានគណៈកម្មាធិការសមាគមកាកបាទក្រហមកម្ពុជា និងបណ្តាក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ២២ សសរ.

## ស្តីពីការបង្កើតគណៈកម្មការ រៀបចំទិវាកីឡាជនពិការកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**សម្រេច**

**ប្រការ ១** : បង្កើតគណៈកម្មការ អន្តរក្រសួងមួយរួមមានអង្គការជាតិ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ប្រធាន
២- តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន អនុប្រធាន
៣- តំណាងក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន
៤- តំណាងក្រសួងមហាផ្ទៃ សមាជិក
៥- តំណាងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ សមាជិក
៦- តំណាងក្រសួងសុខាភិបាល សមាជិក
៧- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៨- តំណាងក្រសួងពត៌មាន សមាជិក
៩- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
១០- តំណាងគណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ សមាជិក
១១- តំណាងក្រសួងការពារជាតិ សមាជិក

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ច ចាត់ចែង និងរៀបចំទិវាកីឡាជនពិការកម្ពុជា ឲ្យបានល្អប្រសើរនៅក្នុងអំឡុងខែមីនាជារៀងរាល់ឆ្នាំ ។

**ប្រការ ៣** : ប្រគល់ភារកិច្ចឲ្យគណៈកម្មការនេះ បង្កើតអនុគណៈកម្មការដែលចាំបាច់ ដើម្បីដំណើរការ ទិវាកីឡាជនពិការកម្ពុជា ។

**ប្រការ ៤** : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ ៥** : សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រធានគណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ ព្រមទាំងអង្គភាពទាំងអស់ ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ២៣ សសរ.**

**ស្តីពីការផ្ទេរភារកិច្ច នៃរាជរដ្ឋាភិបាល**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋឥណ្ឌូនេស៊ី ចាប់ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

# ២- សារាចរណែនាំ

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

## ស្តីពីការជ្រើសរើស និងតែងតាំងមន្ត្រីរាជការស៊ីវិល

***

កន្លងមករាជរដ្ឋាភិបាលបានពិនិត្យឃើញថា មានក្រសួងស្ថាប័នមួយចំនួន បានធ្វើការជ្រើសរើស និងតែងតាំងមន្ត្រីរាជការក្រោមឱវាទពុំសមស្របទៅតាមគោលការណ៍ នៃច្បាប់សហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី និងសារាចរលេខ ០១សរ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ។ ចំពោះមុខដើម្បីពង្រឹងការអនុវត្តន៍ ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋាន ពាក់ព័ន្ធផ្សេងៗ ជុំវិញការគ្រប់គ្រងមន្ត្រី រាជការស៊ីវិលឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីសំដៅបន្តរួមចំណែកក្នុងការអនុវត្តន៍ឲ្យបានជោគជ័យជាស្ថាពរ នូវគោលនយោបាយកំណែទំរង់រដ្ឋបាលសាធារណៈ និងពង្រឹងនីតិរដ្ឋនោះ រាជរដ្ឋាភិបាលសូម ធ្វើការណែនាំដូចខាងក្រោម ៖

### ១- ការជ្រើសរើស :

ក្នុងការជ្រើសរើសមន្ត្រីរាជការស៊ីវិល ចូលក្នុងក្របខ័ណ្ឌរដ្ឋ ត្រូវអនុវត្តតាមបទបញ្ញត្តិដែលមានចែងក្នុងជំពូកទី II នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ជាពិសេសមាត្រា១៣ បានចែងថា "ជាគោលការណ៍រាល់ការជ្រើសរើសបេក្ខជនឲ្យចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយរាជរដ្ឋាភិបាល"។ បែបបទនៃការជ្រើសរើសនេះមានចែងក្នុងសារាចរលេខ ០១ សរ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ ។

### ២- ការតែងតាំងមុខតំណែង :

ជាគោលការណ៍ ការតែងតាំងឲ្យកាន់មុខតំណែងណាមួយនៃមុខងារសាធារណៈរបស់ក្រសួងស្ថាប័ន ត្រូវអនុវត្តចំពោះអ្នករាជការក្របខ័ណ្ឌនៃក្រសួងស្ថាប័ននោះ ។

ការតែងតាំងនោះត្រូវផ្អែកលើសំណូមពរ ភារកិច្ចជាក់ស្តែង សញ្ញាប័ត្រជំនាញ បទពិសោធន៍ការងាររបស់សាមីជនឲ្យសមស្របទៅតាមតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ននីមួយៗ ។ ការតែងតាំងឲ្យកាន់មុខតំណែងមួយក្នុងមុខងារសាធារណៈ ត្រូវអនុវត្តឲ្យបានសមស្របទៅតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលមានចែងជាពិសេសក្នុងមាត្រា ២៨ ជំពូក III ស្តីពីសិទ្ធិក្នុងការតែងតាំង ។

**៣- ការផ្ទេរ :**

រាល់ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ពីក្រសួងស្ថាប័នមួយ ទៅក្រសួងស្ថាប័នមួយទៀត ជាគោលការណ៍ត្រូវមានការឯកភាពពី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**៤- ហាមឃាត់ :**

ក/-តាមស្មារតីខាងលើនេះ មិនត្រូវបានអនុញ្ញាតឲ្យធ្វើការតែងតាំងមុខតំណែងមុខងារសាធារណៈ ក្នុងករណីដូចខាងក្រោម :

- អ្នកដែលគ្មានឈ្មោះក្នុងក្របខ័ណ្ឌមុខងារសាធារណៈ
- អ្នកដែលកំពុងបំពេញកម្មសិក្សា ពុំទាន់តាំងស៊ប់ក្នុងក្របខ័ណ្ឌ ។
- ការតែងតាំងថ្នាក់ស្មើ ក្នុងមុខតំណែងណាមួយ ដោយគ្មានក្នុងរចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងស្ថាប័ន ។
- ការតែងតាំងបន្ថែមចំនួនមន្ត្រី ក្នុងមុខតំណែងអនុប្រធាននាយកដ្ឋាន អនុប្រធានការិយាល័យ អនុប្រធានមន្ទីរនៅខេត្ត-ក្រុង ក្នុងករណីដែលនាយកដ្ឋាន ការិយាល័យ ឬមន្ទីរនោះមានអនុប្រធានចាប់ពី ២នាក់ឡើងទៅរួចហើយ ។ ក្នុងករណីចាំបាច់ត្រូវពិគ្រោះជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យលើរចនាសម្ព័ន្ធជាមុន ។

ខ/- ហាមផ្ទេរបញ្ចូលមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល នូវមន្ត្រីបុគ្គលិកយោធា-នគរបាលជាតិ បុគ្គលិកស្ថិតក្នុងអង្គភាពម្ចាស់ការហិរញ្ញវត្ថុ ស្វ័យភិបាលសេដ្ឋកិច្ច និងក្របខ័ណ្ឌផ្សេងទៀត ដែលមិនស្ថិតនៅក្រោមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។ ក្នុងករណីពិសេសត្រូវមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងទីស្តីការគណៈរដ្ឋមន្ត្រី ។

ទទួលបានសារាចរនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង និងរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តខ្លឹមសារខាងលើនេះ ដោយស្មារតីទទួលខុសត្រូវ និង ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***

# III- ការងារបណ្ដាក្រសួង

## ១- ទីស្ដីការគណៈរដ្ឋមន្ត្រី

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩

**ប្រកាសលេខ ២៨ ប្រក.**

**ស្ដីពីការតែងតាំងមន្ត្រីរាជការ**

**របស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ**

***

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៩អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធ សមាសភាព និងតួនាទីរបស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- យោងតាមសំណើរបស់អនុប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ,

**សំរេច**

**ប្រការ ១** : តែងតាំង :

១- លោក **ស្រ៊ុន ដារិទ្ធិ** ជាអនុប្រធានផ្នែករដ្ឋបាល មានឋានៈស្មើអនុប្រធាននាយកដ្ឋាន

២- លោក **ឈឹម សុខា** ជាអនុប្រធានក្តាប់រួម ផ្នែកកៅស៊ូ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន

៣- លោក **គុំ រ៉ា** ជាអនុប្រធានក្តាប់រួមផ្នែកកសិកម្ម មានឋានៈស្មើអនុប្រធាននាយកដ្ឋាន

៤- លោក **នន្ទ សុពុធិ** ជាអនុប្រធានផ្នែកពសិកម្ម មានឋានៈស្មើអនុប្រធាននាយកដ្ឋាន

៥- លោក ហុង លាងហេង ជាអនុប្រធានគ្រប់គ្រងផ្នែកធនធានទឹក មានឋានៈស្មើអនុប្រធាននាយកដ្ឋាន

៦- លោក ប្រាក់ ម៉ូរិន ជាអនុប្រធានផ្នែកធនធានទឹក មានឋានៈស្មើអនុប្រធាននាយកដ្ឋាន

៧- លោក រ័ត្ន ថិរៈ ជាអនុប្រធានផ្នែកអាជីវកម្មព្រៃឈើ និងជលផល មានឋានៈស្មើអនុប្រធាននាយកដ្ឋាន

៨- លោក សួន ខួនអ៊ី ជាអនុប្រធានផ្នែកអភិវឌ្ឍន៍ជនបទ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន

៩- លោក ផុន ប្រសើរ ផ្នែកអាជីវកម្មព្រៃឈើ និងជលផល មានឋានៈស្មើអនុប្រធានការិយាល័យ

ប្រការ ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលកម្ពុជា នាយកដ្ឋានរដ្ឋបាល-បុគ្គលិក នាយកដ្ឋានផ្គត់ផ្គង់និង ហិរញ្ញកិច្ច នាយកដ្ឋាននានា និង អង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន

★★★

## ៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៩

### ប្រកាសលេខ ១៣៨ ប្រក.សហវ.រតន
### ស្តីពីការបង្កើតប្រព័ន្ធគណនីនៃគណនេយ្យ
### ថវិកាខេត្ត-ក្រុង

***

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង
- បានឃើញ ព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៥/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញ ប្រកាសលេខ ០០៩ ប្រក.សហវ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីប្រព័ន្ធនៃគណនេយ្យនៅរតនាគារជាតិ
- បានឃើញ លិខិតលេខ ១៥៨០ សហវ.ថ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំគំរោងថវិការបស់ខេត្ត-ក្រុង ឆ្នាំ១៩៩៩
- យោងតាមការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១ :** បង្កើត និង ដាក់ឲ្យប្រើនូវប្លង់គណនេយ្យទូទៅមួយ សំរាប់កត់ត្រាឆ្លុះបញ្ចាំងការប្រើប្រាស់ថវិកាផ្ទាល់របស់ខេត្ត-ក្រុង ។ លេខសំគាល់ ឈ្មោះគណនី បញ្ជីរាយនាមគណនី បែបបទទូទៅនៃដំណើរការគណនី ត្រូវរៀបចំដូចមានក្នុងឧបសម្ព័ន្ធទី១ និងទី២ នៃប្រកាសនេះ ។

**ប្រការ ២ :** កិច្ចបញ្ជីការគណនេយ្យរបស់ថវិកាខេត្ត-ក្រុង គឺត្រូវកាន់កាប់ដោយគណនេយ្យករម្នាក់ របស់រតនាគារខេត្ត-ក្រុង ។

**ប្រការ ៣ :** នាយខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធានរតនាគារជាតិ និងប្រធានគ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ ។

**ប្រការ ៤ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**គាត ឈន់**

***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី១

★★★

## បញ្ជីរាយនាមគណនីនៃគណនេយ្យ
## ទូទៅសំរាប់ថវិកា ខេត្ត-ក្រុង

***

| | | | |
|---|---|---|---|
| **គណនីថ្នាក់ ៤ :** | | **គណនីតតិយជន** | |
| | លេខសំគាល់ | | |
| | ៤១២ | អ្នកជាប់ពន្ធ | ឥណាយិក |
| | ៤៥១ | ប្រាក់បញ្ញើរបស់ភ្នាក់ងារបើកផ្តល់ | ឥណទាយី |
| | ៤៦៤ | ប្រាក់តំកល់ធានាបានបង់ | ឥណាយិក |
| | ៤៦៥ | ប្រាក់តំកល់ធានាបានទទួល | ឥណទាយី |
| | ៤៦៨ | ឥណាយិក ឥណទាយី ផ្សេងៗ | ឥណាយិក ឬ ឥណទាយី |
| | ៤៨៧២ | ចំណូលបានពិនិត្យកត់ត្រាមុន | ឥណទាយី |
| **គណនីថ្នាក់ ៥ :** | | **គណនីហិរញ្ញវត្ថុ** | |
| | ៥១៥ | ប្រាក់បញ្ញើនៅរតនាគារខេត្ត-ក្រុង | ឥណាយិក |
| | ៥១៩ | បុរេប្រទានបានទទួលពីរតនាគារខេត្ត-ក្រុង | ឥណទាយី |
| **គណនីថ្នាក់ ៨ :** | | **គណនីទំនាក់ទំនង** | |
| | ៨១៤ | វត្ថុទេយ្យបុរេប្រទាន | ឥណាយិក |
| | ៨១៥ | ប្រាក់បញ្ញើរបស់វត្ថុទេយ្យករបុរេប្រទាន | ឥណទាយី |
| | ៨១៦ | ប្រាក់បញ្ញើរបស់វត្ថុទេយ្យករចំណូល | ឥណទាយី |
| **គណនីថ្នាក់ ៩ :** | | **គណនីវិភាគថវិកា** | |
| | ៩០២ | ចំណូលថវិកាក្នុងឆ្នាំ | ឥណទាយី |
| | ៩១២ | ចំណាយថវិកាក្នុងឆ្នាំ | ឥណាយិក |
| | ៩៧២ | លទ្ធផលនៃការិយបរិច្ឆេទ | ឥណាយិក ឬ ឥណទាយី |

## ប្រព្រឹត្តិកម្មរបស់គណនីនៃគណនេយ្យ
## ថវិកាខេត្ត-ក្រុង

ឧបសម្ព័ន្ធទី២

១- <u>គណនី អ្នកជាប់ពន្ធ អតិថិជន</u> "៤១២"

គណនីនេះ ប្រើសំរាប់កត់ត្រាទឹកប្រាក់ពន្ធ ឬចំណូលដែលអាជីវករ អ្នកជាប់ពន្ធពុំទាន់បានទូទាត់ ។

<u>ឥណពន្ធ</u> : កត់ត្រាចំនួនទឹកប្រាក់ពន្ធត្រូវទារ ដោយយោងតាមសេចក្ដីសំរេច ប្រកាស ការដេញថ្លៃ ការកំណត់ទឹកប្រាក់ ដែលត្រូវទូទាត់ជូនថវិកាខេត្ត-ក្រុង ។

<u>ឥណទាន</u> : កត់ត្រាចំនួនទឹកប្រាក់ ពន្ធ ឬចំណូល ដែលអាជីវករ អ្នកជាប់ពន្ធបានទូទាត់ជាសាច់ប្រាក់ ឬដោយបង្វែរ ។

<u>សមតុល្យ</u> : ឥណាយឹក បង្ហាញអំពីចំនួនទឹកប្រាក់ ពន្ធ ឬចំណូលដែលអាជីវករ អ្នកជាប់ពន្ធពុំទាន់បានទូទាត់ ។

**ចំណាំ** : គណនីនេះ ត្រូវវិភាគទៅតាមអាជីវករ ឬអ្នកជាប់ពន្ធម្នាក់ ។

២- <u>គណនីប្រាក់បញ្ញើរបស់ភ្នាក់ងារបើកផ្ដល់</u> “៥៥១”

គណនីនេះ ប្រើសំរាប់កត់ត្រាប្រាក់បៀវត្សកំរៃត្រូវទូទាត់ជូនបុគ្គលិក ។ ការកត់ត្រា

<u>ឥណពន្ធ</u> : កត់ត្រាចំនួនទឹកប្រាក់បៀវត្ស កំរៃ ត្រូវទូទាត់ជូនបុគ្គលិកតាមការចេញបញ្ជាចំណាយ ។

<u>ឥណទាន</u> : កត់ត្រាចំនួនទឹកប្រាក់ បៀវត្ស កំរៃ ដែលបានដកពីគណនីយកទៅផ្ដល់ជូនបុគ្គលិក ។

<u>សមតុល្យ</u> : ឥណទាយី បង្ហាញអំពីចំនួនប្រាក់កំរៃ បៀវត្ស ដែលនៅពុំបានបើកផ្ដល់ជូនបុគ្គលិក ។

៣- <u>គណនី ប្រាក់តំកល់ធានា ដែលបានបង់</u> “៥៦៤”

គណនីនេះ ប្រើសំរាប់តាមដានប្រាក់ដំកល់ធានា ដែលស្ថាប័នខេត្ត-ក្រុង បានចំណាយសំរាប់កក់ធានាលើការប្រើប្រាស់សេវា ការតំលើង ការបញ្ជាទិញ ។

- <u>ឥណពន្ធ</u> : កត់ត្រាចំនួនទឹកប្រាក់ ដែលស្ថាប័នខេត្តបានចំនាយលើការដំកល់ធានា (តាមរូបភាពសាច់ប្រាក់ ឬបង្វែរ) ។

<u>ឥណទាន</u> : កត់ត្រាចំនួនប្រាក់ទូទាត់លើការដំកល់ធានាបានបង់ តាមរូបភាពចំណូលជាសាច់ប្រាក់ ឬបង្វែរមកវិញ ឬទូទាត់ជាមួយបញ្ជាចំណាយ ។

<u>សមតុល្យ</u> : ឥណាយឹកប្រាក់ដំកល់ធានាបានបង់ពុំទាន់បានទូទាត់វិញ ។

<u>ចំណាំ</u> : គណនីនេះ ត្រូវបើកលំអិតទៅតាមអង្គភាពអាជីវករ ដែលបានទទួលប្រាក់ដំកល់ពីខេត្ត-ក្រុង ។

៤- <u>គណនី ប្រាក់តំកល់ធានាបានទទួល</u> “៥៦៥”

គណនីនេះប្រើសំរាប់តាមដានប្រាក់កក់ ដំកល់ធានា លើសកម្មភាពអាជីវកម្មដែលស្ថាប័នខេត្ត-ក្រុងបានទទួល ។ យោងតាមសេចក្ដីសំរេចកំណត់ហេតុ កិច្ចសន្យា និងតាមការបង់ប្រាក់ជាក់ស្ដែង ។

<u>ឥណទាន</u> : កត់ត្រាចំនួនប្រាក់ ដែលអាជីវកម្មបានបង់ចូល យោងតាមប័ណ្ណបង់ប្រាក់ ឬប័ណ្ណបង្វែរ ។

ឥណពន្ធ : កត់ត្រាចំនួនប្រាក់ដែលបានសងអាជីវករវិញ (ដោយសាច់ប្រាក់ ឬបង្វែរ) ចំនួនប្រាក់ដែលអាជីវករផ្ទេរបង់ជាចំណូលថវិកាខេត្ត-ក្រុង (ផ្អែកតាមសាលាកប័ត្រចំណូល)

សមតុល្យ : ឥណទាន បង្ហាញអំពីចំនួនប្រាក់កក់ធានាអាជីវកម្មបានទទួលពុំទាន់បានបែងចែក ។

៥- គណនី ឥណពន្ធ ឥណទាន ផ្សេងៗ "៤៦៨"

គណនីនេះ ប្រើសំរាប់ធ្វើអន្តរការីយនូវខ្ទង់ត្រូវសង ត្រូវទារផ្សេងៗ

ឥណពន្ធ : កត់ត្រាខ្ទង់ទឹកប្រាក់ត្រូវទារ ទឹកប្រាក់ត្រូវសង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ត្រូវសង ទឹកប្រាក់ទារបាន

សមតុល្យ : ឥណពន្ធ បង្ហាញអំពីខ្ទង់ទឹកប្រាក់ត្រូវទារ

សមតុល្យ : ឥណទាន បង្ហាញអំពីទឹកប្រាក់ត្រូវសង

៦- គណនី ចំណូលបានពិនិត្យកត់ត្រាមុន "៤៧២"

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ពន្ធ ឬចំណូលផ្សេងទៀត ដែលអាជីវករត្រូវបង់ចូលថវិកាខេត្ត-ក្រុង ។ កត់ត្រាចំនួនទឹកប្រាក់បន្ធូរបន្ថយ ឬលុបចោលទឹកប្រាក់ពន្ធ ឬចំណូលផ្សេងៗ ដោយយោងតាមសេចក្តីសំរេចប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលអាជីវករ ឬអ្នកជាប់ពន្ធបានទូទាត់ជាសាច់ប្រាក់ឬដោយបង្វែរចូលគណនីប្រាក់បញ្ញើថវិកា ខេត្ត-ក្រុង ( ជាលេខនាទន្ទឹម និង លេខនាចំណូលរតនរត្ថ) ។

សមតុល្យ : ឥណទានបង្ហាញអំពីចំណូលបានពិនិត្យកត់ត្រាមុន ដែលអាជីវករពុំទាន់បានបង់ចូលថវិកាខេត្ត-ក្រុង ។

៧- គណនី ប្រាក់បញ្ញើរបស់ខេត្ត-ក្រុងនៅរតនាគារ "៥១៥"

គណនីនេះ ប្រើសំរាប់កត់ត្រាចំនួនប្រាក់ (មូលនិធិ) ដែលស្ថាប័នខេត្ត-ក្រុង បានផ្ញើនៅរតនាគារខេត្ត-ក្រុង ។

ឥណពន្ធ : ចំនួនទឹកប្រាក់ដែលស្ថាប័នខេត្ត-ក្រុង បានផ្ញើនៅរតនាគារ (ជាសាច់ប្រាក់ឬបង្វែរ) ។

ឥណទាន : ចំនួនប្រាក់ដែលស្ថាប័នខេត្ត-ក្រុង បានដកចេញពីរតនាគារ ដោយសាច់ប្រាក់ ឬបង្វែរ ។

សមតុល្យ : ឥណពន្ធបង្ហាញអំពីចំនួនប្រាក់របស់ខេត្ត-ក្រុង នៅសល់កំពុងផ្ញើទុកនៅរតនាគារខេត្ត-ក្រុង ។ គណនីនេះ ត្រូវផ្ទៀងផ្ទាត់ជាទៀងៗ ជាពិសេសនៅរាល់ដំណាច់ខែជាមួយគណនេយ្យកម្មរបស់រតនាគារខេត្ត-ក្រុង (គណនី ៤២៥) ។

៨- គណនី បុរេប្រទានពីរតនាគារខេត្ត-ក្រុង “៥១៩”

គណនីនេះ ប្រើសំរាប់តាមដានចំនួនទឹកប្រាក់បុរេប្រទាន ដែលស្ថាប័នខេត្ត-ក្រុង បានខ្ចីជាបណ្តោះអាសន្នពីរតនាគារខេត្ត-ក្រុង ដោយមានការសំរេចពីថ្នាក់លើ ។ សមតុល្យគណនីនេះមានអត្ថិភាពតែពេលខ្ចីតែប៉ុណ្ណោះ ក្នុងរង្វង់មួយខែ ។

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បុរេប្រទាន ដែលស្ថាប័នខេត្ត-ក្រុង បានទទួលពីរតនាគារ ដោយយោងតាមការសំរេចពីថ្នាក់លើ ។

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់សងទៅរតនាគារខេត្ត-ក្រុងវិញ តាមរូបភាពបង្វែរ ។

សមតុល្យ : ឥណទាយី បង្ហាញអំពីចំនួនប្រាក់ដែលស្ថាប័នខេត្ត-ក្រុង ជំពាក់រតនាគារ ស្តីពីប្រាក់បុរេប្រទានពុំទាន់បានទូទាត់ ។

ចំណាំ : រាល់ការសុំបុរេប្រទាន សុទ្ធតែត្រូវបញ្ជូលទៅក្នុងគណនីបញ្ញើមូលនិធិរបស់ស្ថាប័នខេត្ត-ក្រុង នៅរតនាគារជាតិខេត្ត-ក្រុងសិន ទើបចំណាយ ។

៩- គណនីរដ្ឋទេយ្យបុរេប្រទាន “៨១៤”

គណនីនេះ ប្រើសំរាប់កត់ត្រាតាមដាន នូវចំនួនទឹកប្រាក់ក៏រិតកំណត់ បុរេប្រទានតាមរដ្ឋទេយ្យ ដែលអន្តរមន្ទីរ ក្រសួងបានឯកភាពគ្នានឹងបានអនុម័ត ។

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ក៏រិតកំណត់រដ្ឋទេយ្យបុរេប្រទាន ដែលបានកំណត់ (ដោយប្រកាសរួម) ជាលើកដំបូង ។

កត់ត្រាចំនួនទឹកប្រាក់ ដែលសំរេចបន្ថែមក៏រិតកំណត់រដ្ឋទេយ្យបុរេប្រទាន ។

ឥណទាន : កត់ត្រាបន្ថយក៏រិតកំណត់រដ្ឋទេយ្យបុរេប្រទាន ។

កត់ត្រាលុបចោលនូវក៏រិតកំណត់ រដ្ឋទេយ្យបុរេប្រទាន ។

សមតុល្យ : ឥណយីក បង្ហាញអំពីក៏រិតកំណត់នៃរដ្ឋទេយ្យបុរេប្រទានកំពុងអនុវត្ត ។

១០- គណនី ប្រាក់បញ្ញើរដ្ឋទេយ្យបុរេប្រទាន “៨១៥”

គណនីនេះ ប្រើសំរាប់កត់ត្រាតាមដានប្រាក់បញ្ញើរដ្ឋទេយ្យបុរេប្រទានរបស់សាលាខេត្ត-ក្រុង ។

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បញ្ញើដើមដំបូងរបស់រដ្ឋទេយ្យបុរេប្រទាន ( យោងតាមប្រកាសរួម)

- កត់ត្រាចំនួនទឹកប្រាក់ចំណាយ (តាមរដ្ឋទេយ្យបុរេប្រទាន) ដែលបានទូទាត់វិញតាមបញ្ជាចំណាយ ។
- កត់ត្រាចំនួនទឹកប្រាក់បន្ថែមក៏រិតកំណត់រដ្ឋទេយ្យបុរេប្រទាន ។

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលរដ្ឋទេយ្យករបានដកយកទៅ ដើម្បីចំណាយ ។

សមតុល្យ : ឥណទាយី បង្ហាញអំពីចំនួនប្រាក់បញ្ញើរបស់រដ្ឋទេយ្យករកំពុងមាន ។

១១- គណនី រដ្ឋទេយ្យចំណូល "៩១៦"

គណនីនេះ ប្រើសំរាប់កត់ត្រាតាមដានចំនួនប្រាក់ ដែលរដ្ឋទេយ្យករចំណូលបានបង់ ឬបានបង្វែរចូលថវិកាខេត្ត-ក្រុង ។

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលរដ្ឋទេយ្យករទទួលបាន ហើយយកមកបង់ចូលគណនីប្រាក់បញ្ញើខេត្ត-ក្រុង (បង់ដោយសាច់ប្រាក់ ឬដោយបង្វែរ) ។

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលរដ្ឋទេយ្យករបានបង្វែរចូលទៅថវិកាខេត្ត-ក្រុង ជាស្ពាន។

សមតុល្យ : ឥណទានបង្ហាញអំពីចំនួនប្រាក់បញ្ញើរបស់រដ្ឋទេយ្យករចំណូល ពុំទាន់បានបង្វែរចូលថវិកាខេត្ត-ក្រុង ។

១២- គណនីចំណូលថវិកាខេត្ត-ក្រុង "៩០២"

គណនីនេះ ប្រើសំរាប់កត់ត្រាតាមដានចំណូលថវិកាខេត្ត-ក្រុង ដែលបានចំណូលដោយសាច់ប្រាក់ ដោយបង្វែរផ្នែកតាមសលាកប័ត្របង់ចំណូល ។

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ ចំណូលថវិកាខេត្ត-ក្រុង ។

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យឥណទាន (ចំណូលបូកបន្តពីដើមការិយបរិច្ឆេទ) ចូលគណនីលទ្ធផល ។

សមតុល្យ :ឥណទានបង្ហាញអំពីចំនួនប្រាក់ចំណូលថវិកាបូកបន្ត ពុំទាន់ផ្ទេរទៅគណនីលទ្ធផល

១៣- គណនី ចំណាយថវិកាខេត្ត-ក្រុង "៩១២"

គណនីនេះ ប្រើសំរាប់កត់ត្រាតាមដានចំណាយថវិកា តាមរយៈការផ្សាយចេញនូវបញ្ជាចំណាយ ។

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ចំណាយថវិកាខេត្ត-ក្រុង តាមបញ្ជាចំណាយ និងបន្ថយប្រាក់ចំណាយថវិកា ដោយសញ្ញា " - " ។

ឥណទាន : កត់ត្រាផ្ទេរសមតុល្យឥណពន្ធ (បូកបន្តពីដើមការិយបរិច្ឆេទ) ចូលទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ កំពុងអនុវត្ត ។

សមតុល្យ : ឥណពន្ធបង្ហាញអំពីចំនួនប្រាក់ចំណាយថវិកាបូកបន្ត ពុំទាន់ផ្ទេរទៅលទ្ធផលនៃការិយបរិច្ឆេទ ។

១៤- គណនី លទ្ធផលនៃការិយបរិច្ឆេទ "៩៧២"

គណនីនេះ ប្រើសំរាប់ទូទាត់វិសមភាព រវាងចំណូល និងចំណាយថវិកា ។ លទ្ធផលជាការប្រមូលផ្តុំចំណូល និងចំណាយនៅថ្ងៃ៣១ ខែ១២ នៃការិយបរិច្ឆេទ ។

ឥណពន្ធ : កត់ត្រាសមតុល្យឥណពន្ធ នៃគណនីចំណាយថវិកាផ្ទេរមក ។

ឥណទាន : កត់ត្រាសមតុល្យឥណទាន នៃគណនីចំណូលថវិកាផ្ទេរមក ។

សមតុល្យ : ឥណពន្ធ បង្ហាញអំពីឱនភាពថវិកា ខេត្ត-ក្រុង ។ ឬ

សមតុល្យ : គណនាយើ បង្ហាញអំពីអតិរេក (លើស) ថវិកាខេត្ត-ក្រុង ។
ជាគោលការណ៍មិនអនុញ្ញាតអោយមានសមតុល្យគណនាយើកឡើយ ។

★★★

## ២- នីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៩

**ប្រកាសលេខ ២៨៣ ឧក.ប្រក.**

***

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២១៥៤/៩៧ កអក. ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ១៩៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៣៥៨៧ សអស. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ១៩៩៨ របស់សាលាក្រុងភ្នំពេញស្តីពីការអនុញ្ញាតឲ្យសាងសង់អាគាររោងចក្រកាត់ដេរ
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អ័រឈីត ហ្គាមិន ខូ.. លីមីធីត ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។

**សំរេច**

**ប្រការ ១.**_ អនុញ្ញាតឲ្យក្រុមហ៊ុន អ័រឈីត ហ្គាមិន ខូ .. លីមីធីត (ORCHID GARMENT Co., LTD) តំណាងដោយលោកស្រី EAR YEK LANG សញ្ជាតិ អូស្ត្រាលី អាយុ ៣០ឆ្នាំ អាសយដ្ឋាន 1418 Man Yue House TSZ Man Estate Kowloon, HONG KONG កាន់លិខិតឆ្លងដែនលេខ E7006623 ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៥ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលមានឈ្មោះថា "រោងចក្រកាត់ដេរ អ័រឈីត ហ្គាមិន " មានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវពីស្ថានីយវិទ្យុស្ទឹងមានជ័យ ទៅចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់ និង រៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឲ្យបានសំរេចក្នុងរយៈពេល ០៣ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាយការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ "កាត់-ដេរ សំលៀកបំពាក់" ទៅតាមគំរូដែលតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅយកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន អ័រណេបឺត ហ្គាម៉ិន ខូ.. លីមីធីត ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពតតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ស៊ុយ សែម

★★★

## ៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

**ប្រកាសលេខ ៧៤៨ ពណ.ខកល.**

**ស្តីពីការកែសំរួល និង បំពេញបន្ថែមមាត្រាមួយចំនួន**

**នៃប្រកាសលេខ ៦៦៥ ពណ.ខកល.៩៩ ស្តីពីដាក់ដេញថ្លៃលើកូតា**

**នាំចេញសំលៀកបំពាក់ទៅសហរដ្ឋអាមេរិក**

***

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស រោមចៀម សរសៃ សិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិកប្បាស និង សរសៃសូត្ររវាងរាជរដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៩៩ ។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ៣៦០ MoC/M99 ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងកូតាសំរាប់ការនាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ ដែលជាកម្មវត្ថុនៃការកំណត់បរិមាណដោយសហរដ្ឋអាមេរិក ។
- យោងតាមសំណើរបស់ក្រសួងពាណិជ្ជកម្មលេខ ៦៦៥ ពណ.ខកល ៩៩ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការដាក់ដេញថ្លៃលើកូតានាំចេញសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ។
- យោងតាមការចាំបាច់នៃការងារ ។

**សំរេច**

**ប្រការ ១ :** នៅក្នុងប្រការ២ នៃសេចក្តីប្រកាសលេខ ៦៦៥ ពណ.ខកល ៩៩ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៩៩ ចំពោះប្រភេទសំលៀកបំពាក់លេខ ៣៤៧/៣៤៨/៦៤៧/៦៤៨ ដែលត្រូវបានដាក់ឲ្យដេញថ្លៃមានចំនួន ២១២,៥០០ ឡូត៍ ត្រូវបានកែសំរួលទៅជាចំនួន ២១៧,៥០០ ឡូតិ៍វិញ ។ ឯខ្លឹមសារក្រៅពីនោះត្រូវបានរក្សាទុកនៅដដែល ។

**ប្រការ ២ :** ប្រការ ១៣ នៃប្រកាសលេខ ៦៦៥ ពណ.ខកល ៩៩ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៩៩ ត្រូវបានកែសំរួលជាថ្មី ដែលមានខ្លឹមសារដូចខាងក្រោម ៖

-អ្នកដេញថ្លៃដែលបានទទួលជោគជ័យ អាចនឹងអនុវត្តការទទួលយកកូតារបស់ខ្លួនបាន នៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៩ ដោយត្រូវទូទាត់តំលៃដេញថ្លៃសរុបឲ្យរួចក្នុងរយៈពេលចាប់ពីថ្ងៃដេញថ្លៃបានរហូតដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩ វេលាម៉ោង ១៧:០០ ។ ប្រសិនបើក្រុមហ៊ុនណា

អ្នកមានប័ណ្ណផ្ទេរកូតាឲ្យទៅក្រុមហ៊ុនផ្សេងទៀត ក្រុមហ៊ុនដែលមានប័ណ្ណផ្ទេរនោះត្រូវបង់ប្រាក់ចំនួន ៩០% និងបង់តេការ៉ែការផ្ទេរឲ្យជាប់សព្វគ្រប់សិន ទើបអនុញ្ញាតឲ្យធ្វើការផ្ទេរ ។

ប្រការ ៣ : អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និងសមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ ។ ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខា និង ត្រា
**ចម ប្រសិទ្ធ**

★★★

# ៤- នីតិការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ១- ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩

**ប្រកាសលេខ ១៥៣ អយក.ប្រក.**

**ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ**

**ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ**

***

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីអំពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ ។
- បានឃើញលិខិតឧទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២២៣៧ សជណ.អវ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ១៩៨០ ស្ដីពីការប្ដូរឈ្មោះសាលាករៀនចំនេះទូទៅ ។
- បានឃើញលិខិតរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីលេខ ៨០៧ សជណ.អរ. ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៥ ស្ដីពីការអនុញ្ញាតជាគោលការណ៍ឲ្យប្រឡងសញ្ញាប័ត្រមធ្យមសិក្សាពីរលើក ។

- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**សំរេច**

**ប្រការ ១ :** មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិលើកទី១ និង លើកទី២ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា រៀងរាល់ឆ្នាំសិក្សា ។

**ប្រការ ២ :** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង និង នាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានត្រូវបានកំណត់ជាមណ្ឌលប្រឡងមានភារៈរៀបចំបន្ទប់ប្រលងកំរងសលាកប័ត្រឯកត្តជនរបស់បេក្ខជន បញ្ជីផ្សេងៗ និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តិទៅនៃការប្រឡង ឲ្យហើយស្រេច មុនបើកសម័យប្រលង ។

-ចំពោះសាលារៀនក្រោមឱវាទផ្ទាល់នៃក្រសួងអប់រំ យុវជន និងកីឡា នាយកគ្រឹះស្ថានសិក្សាក៏ត្រូវអនុវត្តដូចមណ្ឌលនានាដែរ តាមការណែនាំរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**ប្រការ ៣ :** មណ្ឌលប្រឡងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និង សមាជិកគណៈមេប្រយោគមួយចំនួនតាមការចាំបាច់នៃមណ្ឌលប្រឡង ។

**ប្រការ ៤ :** សមាសភាព និង ចំនួនព្រមទាំងលិខិតឧទ្ទេសនាមគណៈមេប្រយោគត្រូវសំរេចដោយ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមសំណើរបស់ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**ប្រការ ៥ :** ចំនួនអនុរក្ស នៃមណ្ឌលប្រឡង ត្រូវគិតតាមចំនួនបន្ទប់ប្រឡង គុណនឹង ២,៥ ។

**ប្រការ ៦ :** បន្ទប់ប្រឡងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹម ២៥ "ម្ភៃប្រាំ" នាក់ ។ បើមានបេក្ខជននៅសល់ ០៥ "ប្រាំ" នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក ។

**ប្រការ ៧ :** ប្រធានគណៈមេប្រយោគនៃមណ្ឌលនីមួយៗ ជាអ្នកទទួលខុសត្រូវរួមក្នុងការដំណើរការប្រព្រឹត្តទៅនៃការប្រឡងទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសចំពោះក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៨ :** ប្រធានគណៈមេប្រយោគ ត្រូវសហការ ឬ ធ្វើអន្តរាគមន៍ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត-ក្រុងនៃមណ្ឌលប្រឡង ក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រឡង ។

**ប្រការ ៩ :** មណ្ឌល ឬ អនុមណ្ឌលប្រឡងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍ នៃការប្រលង ប្រធានគណៈមេប្រយោគនៃមណ្ឌល ឬ អនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មកគណៈមេប្រយោគ ទូទាំងប្រទេស និងអាជ្ញាធរដែនដី ដើម្បីដោះស្រាយ ឬសុំការសំរេចពីក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ១០ :** ប្រធានគណៈមេប្រយោគត្រូវ បែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិកគណៈមេប្រយោគ ឲ្យទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន ។

**ប្រការ ១១ :** ភារកិច្ចគណៈកម្មការ អនុគណៈកម្មការ និងសមាជិកនៃគណៈមេប្រយោគនឹងមានចែងក្នុងសេចក្តីណែនាំមួយរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ១២ :** នឹងអនុញ្ញាតឲ្យចុះឈ្មោះប្រលងលើកទី១ បានសិស្សថ្នាក់ទី១២ នៃវិទ្យាល័យសាធារណៈ និង ឯកជនដែលបានរៀនជប់កម្មវិធីសិក្សាថ្នាក់ទី១២ និង គោរពបានត្រឹមត្រូវបាននូវបទបញ្ញា ផ្ទៃក្នុងសំរាប់

គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតំលៃផ្នែកសិលធម៌ប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ និង អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។ ពាក្យសុំចុះឈ្មោះប្រឡង មានពិទតែម ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា តាមឋានានុក្រម ។

ប្រការ ១៣ : នឹងអនុញ្ញាតឲ្យចូលរួមប្រឡងលើកទី ២ បាន ៖

- បេក្ខជន ដែលប្រលងធ្លាក់លើកទី១ និង បានពិន្ទុប្រលងនៃការប្រឡង សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិលើកទី១ ចាប់ពីពិន្ទុ ១៧៥ ឡើងទៅ ។
- បេក្ខជនដែលបានដាក់ពាក្យសុំប្រលងលើកទី១ តែអាក់ខានពុំបានចូលរួមប្រឡង ឬ បានចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជា ដោយមូលហេតុមានជំងឺ ឬ គ្រោះថ្នាក់ផ្សេងៗជាក់ស្តែង ហើយមានពាក្យសុំច្បាប់ត្រឹមត្រូវដោយមានការបញ្ជាក់ពីឪពុកម្តាយ ឬ អាណាព្យាបាលស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡាតាមរយៈប្រធានមណ្ឌលដែលសាមីខ្លួនត្រូវប្រឡង ។
- បេក្ខជនស្វ័យរិនដែលប្រលងធ្លាក់លើកទី១ និង បានពិន្ទុប្រឡងថ្នាក់ជាតិលើកទី១ ចាប់ពីពិន្ទុ ១៥០ឡើងទៅ ។

ប្រការ ១៤ : អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ជាបេក្ខជនស្វ័យរិនបានអតីតបេក្ខជនដែលបានប្រឡងធ្លាក់ សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។

ប្រការ ១៥ : បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រឡងរបស់ខ្លួននូវ ៖

- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ ១ សន្លឹក
- សលាកប័ត្រឯកត្តជនទំហំ ១៥ ស.ម គុណនឹង ២១ស.ម មានបិទ រូបថតថ្មីថតចំពីមុខទំហំ ៤ស.ម គុណនឹង ៦ស.ម ចំនួន ៤សន្លឹក ។
- បង្កាន់ដៃបង់សិទ្ធិប្រលង ១ ច្បាប់
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ៤ស.ម គុណនឹង ៦ស.ម "រូបថតដែលបានបិទលើសលាកប័ត្រឯកត្តជន" ចំនួនបីសន្លឹក ។
- សៀវភៅសិក្ខាគារិក "ចំពោះសិស្សសាលាឯកជន" ។

ប្រការ ១៦ : ពាក្យសុំចុះឈ្មោះប្រឡងលើកទី១ និង លើកទី២ នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សាដែលខ្លួនសិក្សា ។ នាយកគ្រឹះស្ថានសិក្សាត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដើម្បីធ្វើការបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្ខរក្រមទៅតាមបន្ទប់ប្រឡង។

ប្រការ ១៧ : បេក្ខជនដែលបានប្រកាសថា ត្រូវបានប្រលងលើកទី២ មិនបាច់ដាក់ពាក្យសុំប្រលងទៀតទេ ។ មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុងមានភារៈរៀបចំបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្ខរក្រមទៅតាមបន្ទប់ប្រឡង ។

ប្រការ ១៨ : បេក្ខជនស្វ័យរិន ត្រូវដាក់ពាក្យសុំប្រលងលើកទី១ ដោយមានបញ្ជាក់សម័យប្រឡង មណ្ឌលប្រឡង លេខបន្ទប់ លេខតុ នៃសម័យប្រឡងមុន នៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង

ដែលសាមីខ្លួនបានសុំប្រឡងពីមុន ឬ នៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ១៩ :** មន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង ត្រូវធ្វើបញ្ជីរាយនាមបេក្ខជន ផ្ញើទៅក្រសួងអប់រំ យុវជន និង កីឡា "នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ" ដើម្បីពិនិត្យនិងសំរេចលើបេក្ខភាព ។

**ប្រការ ២០ :** បេក្ខជនត្រូវអនុវត្តតាមបទបញ្ញត្តិទូទៅនៃការប្រលង ដែលមានចែងក្នុងអត្ថបទមួយដោយឡែក ។

**ប្រការ ២១ :** វិញ្ញាសា ថេរវេលា និង ពិន្ទុនៃការប្រលង សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិលើកទី១ និង លើកទី២ ត្រូវបានកំណត់ដូចតទៅ ៖

១- តែងសេចក្តី រយៈពេល ២ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០

២- គណិតវិទ្យា រយៈពេល ២ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០

៣- វិទ្យាសាស្ត្រពិត រយៈពេល ២ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០

ក្នុងនោះ ៖

-រូបវិទ្យា រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៤

-គីមី រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៣

-ជីវវិទ្យា រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៣

៤- វិទ្យាសាស្ត្រសង្គម រយៈពេល ២ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០

ក្នុងនោះ ៖

-ទស្សនវិជ្ជា រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៤

-ប្រវត្តិវិទ្យា រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៣

-ភូមិវិទ្យា រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៣

វិញ្ញាសានីមួយៗនឹងត្រូវបានពិន្ទុសូន្យចំពោះបេក្ខជនអវត្តមាន ឬ បេក្ខជនដែលមិនបានប្រគល់សន្លឹកកិច្ចការដល់គណៈមេប្រយោគ ។

**ប្រការ ២២ :** ប្រធានវិញ្ញាសាប្រឡង ត្រូវយកតាមកម្មវិធីថ្នាក់ទី១២ នៃមធ្យមសិក្សាទុតិយភូមិ ។ វិញ្ញាសាទាំងឡាយជាវិញ្ញាសាសរសេរទាំងអស់ ។

**ប្រការ ២៣ :** ប្រធានវិញ្ញាសាទាំងឡាយត្រូវជ្រើសរើស ឬ តាក់តែងដោយក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ២៤ :** ប្រធានវិញ្ញាសាទាំងឡាយ ដែលបានជ្រើសរើសរួចហើយ ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត និងប្រថាប់ត្រា ហើយត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដែលមានមណ្ឌលប្រឡងតាមរយៈមេប្រយោគទូទាំងប្រទេសឲ្យថែរក្សាទុក ៣៦ ម៉ោងមុនពេលប្រកាសចាប់ផ្តើមប្រឡង ។

**ប្រការ ២៥ :** អាជ្ញាធរមានសមត្ថកិច្ច ដែលថែរក្សាវិញ្ញាសាទាំងនោះ ត្រូវប្រគល់ឲ្យគណៈមេប្រយោគទូទាំងប្រទេសនៅថ្ងៃចាប់ផ្តើមការប្រឡងមួយម៉ោង មុនពេលបើកសម័យប្រឡង ។

**ប្រការ ២៦ :** ការប្រគល់ឲ្យ និង ការទទួលយកវិញ នូវប្រធានវិញ្ញាសាប្រឡងត្រូវមានការទទួលខុសត្រូវទាំងសងខាង ដោយមានកំណត់ហេតុជាផ្លូវការផង ។

ប្រការ ២៧ : វិញ្ញាសានីមួយៗ ត្រូវមានចំនួនសន្លឹកវិញ្ញាសា ស្មើនឹងចំនួនបេក្ខជន ។ បើខ្វះត្រូវចំឡងបន្ថែមបង្គប់ភ្លាម ។

ប្រការ ២៨ : វិញ្ញាសាសរសេរនីមួយៗ ត្រូវកែដោយសមាជិកកំណែពីរនាយក់ជាផ្ដាច់ខាត តាមតារាងអត្រាកំនែដែលគណៈមេប្រយោគបានសំរេច ។

ប្រការ ២៩ : ពិន្ទុសរុបនៃពិន្ទុគ្រប់វិញ្ញាសាហៅថា ពិន្ទុប្រឡងថ្នាក់ជាតិ ជាពិន្ទុលើ ៥០០ ។

ប្រការ ៣០ : ពិន្ទុប្រចាំឆ្នាំស្មើនឹងមធ្យមភាគពិន្ទុប្រចាំឆមាសទី១ បូកនិងមធ្យមភាគពិន្ទុប្រចាំឆមាសទី២ ជាពិន្ទុលើ ១០០ ។

ប្រការ ៣១ : ពិន្ទុប្រឡងស្មើនឹងពិន្ទុប្រចាំឆ្នាំបូកនិងពិន្ទុប្រលងថ្នាក់ជាតិ ។

ប្រការ ៣២ : នឹងត្រូវប្រកាសថាប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បេក្ខជននៃវិទ្យាល័យសាធារណៈ និងឯកជន ទាំងឡាយណាដែលបានពិន្ទុប្រឡងចាប់ពី២៥០ ឡើងទៅ និងបេក្ខជនស្វ័យរិនទាំងឡាយណាដែលបានពិន្ទុប្រឡងថ្នាក់ជាតិចាប់ពី ២០០ ឡើងទៅ ដោយឥតមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយ ។

ក្នុងករណីចាំបាច់គណៈមេប្រយោគអាចធ្វើសំរង់ឲ្យជាប់បន្ថែមក្រោយពីមានការយល់ព្រមពីក្រសួងអប់រំ យុវជន និង កីឡាតាមភាពជាក់ស្ដែង និង តាមសំនើរបស់គណៈមេប្រយោគ ។ បេក្ខជនស្វ័យរិនមិនធ្វើសំរង់ឲ្យជាប់បន្ថែមឡើយ ។

ប្រការ ៣៣ : គណៈមេប្រយោគមណ្ឌលប្រឡងនីមួយៗ ត្រូវប្រជុំពិភាក្សារួមដើម្បីសំរេចលទ្ធផលនៃការប្រឡង។ កំណត់ហេតុ និង បញ្ជីចាំបាច់នានាភ្ជាប់មកជាមួយ ត្រូវបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡាជាតិរ ច្បាប់ ដើម្បីសុំសេចក្ដីយល់ព្រម ។

ប្រការ ៣៤ : និទ្ទេសត្រូវបានកំណត់តាមពិន្ទុប្រឡងដូចតទៅ ៖

* ចំពោះបេក្ខជននៃវិទ្យាល័យសាធារណៈ និង ឯកជន :

| | | |
|---|---|---|
| ចាប់ពីពិន្ទុ ២៥០ | ទៅពិន្ទុ ៣២៤,៩៩ | និទ្ទេស មធ្យម |
| ចាប់ពីពិន្ទុ ៣២៥ | ទៅពិន្ទុ ៣៩៩,៩៩ | និទ្ទេស ល្អបង្គួរ |
| ចាប់ពីពិន្ទុ ៤០០ | ឡើងទៅ | និទ្ទេស ល្អ |

* ចំពោះបេក្ខជនស្វ័យរិន :

| | | |
|---|---|---|
| ចាប់ពីពិន្ទុ ២០០ | ទៅពិន្ទុ ២៥៩ | និទ្ទេស មធ្យម |
| ចាប់ពីពិន្ទុ ២៦០ | ទៅពិន្ទុ ៣១៩ | និទ្ទេស ល្អបង្គួរ |
| ចាប់ពីពិន្ទុ ៣២០ | ឡើងទៅ | និទ្ទេស ល្អ |

ប្រការ ៣៥ : នឹងត្រូវប្រកាសថា ត្រូវបានប្រឡងលើកទី២ បេក្ខជនទាំងឡាយណា ដែលមិនបានប្រកាសថាប្រឡងជាប់លើកទី១ ហើយបានពិន្ទុប្រឡងចាប់ពី ១៧៥ ឡើងទៅ (ចំពោះបេក្ខជននៃវិទ្យាល័យសាធារណៈ និង ឯកជន) និងបានពិន្ទុប្រឡងថ្នាក់ជាតិចាប់ពី ១៤០ ឡើងទៅ (ចំពោះបេក្ខជនស្វ័យរិន) ដោយមិនគិតពិន្ទុសូន្យចំពោះមុខវិជ្ជាណាមួយឡើយ ។

**ប្រការ ៣៦ :** បទបញ្ញត្តិ ស្តីពីការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ពីមុនៗទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣៧ :** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ និង ប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ដើម្បីឲ្យបានសំរេចនូវប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
តុល ឡោះ

★★★

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩

**ប្រកាសលេខ ១៦០ អយក.ប្រក.**

**ស្តីពីការពង្រីកអនុវិទ្យាល័យ សម្តេច ហ៊ុន សែន ពាមជីលាំង**
**ទៅជាវិទ្យាល័យ ហ៊ុន សែន ពាមជីលាំង ស្ថិតនៅក្នុង ឃុំពាមជីលាំង**
**ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម**

***

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ/បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត ២
- យោងលិខិតស្នើសុំ របស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យ សម្តេច ហ៊ុន សែន "ពាមជីលាំង" ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្ត កំពង់ចាម

- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**សម្រេច**

**ប្រការ ១ :** អនុញ្ញាតឲ្យពង្រីកអនុវិទ្យាល័យ សម្តេច ហ៊ុន សែន "ពាមជីលាំង" បច្ចុប្បន្នទៅជាវិទ្យាល័យ ហ៊ុន សែន "ពាមជីលាំង" ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ។

**ប្រការ ៣ :** នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ប្រធាន នាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានអប់រំយុវជន និងកីឡាខេត្តកំពង់ចាម និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
**អ៊ឹម សិទ្ធី**

★★★

## ២- សេចក្តីណែនាំ

### សេចក្តីណែនាំលេខ ៧២៧ អយក.សណន
### ស្តីពីការរៀបចំថ្នាក់សិស្សពូកែនៅតាមគ្រឹះស្ថានមធ្យមសិក្សា
### និងការប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

***

យោងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៨ និងសារាចរណែនាំលេខ ០៩ អយក.សរណន ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំថ្នាក់សិស្សថ្នាក់ពូកែនៅតាមគ្រឹះស្ថានមធ្យមសិក្សា និង ការប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងយោងសារាចរណែនាំលេខ ០៣អយក.សរណន ចុះថ្ងៃ០១ ខែមេសា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ រចនាសម្ព័ន្ធ អប់រំ យុវជន និងកីឡាខេត្ត-ក្រុង និងការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ-ស្រុក ។ ចាប់ពីឆ្នាំសិក្សា១៩៩៨-៩៩ តទៅ ក្រសួងអប់រំ យុវជន និង កីឡា សូមធ្វើការណែនាំ ស្តីពីការរៀបចំថ្នាក់សិស្សពូកែ ផ្នែកមធ្យមសិក្សាដែលមានខ្លឹមសារដូចខាងក្រោម :

១- ថ្នាក់សិស្សពូកែតាមគ្រឹះស្ថានមធ្យមសិក្សា :

- នៅរៀងរាល់ដើមឆ្នាំសិក្សា តាមគ្រឹះស្ថានមធ្យមសិក្សានីមួយៗគប្បីរៀបចំថ្នាក់សិស្សពូកែ ផ្នែកគណិតវិទ្យា និង អក្សរសិល្ប៍ខ្មែរ តាមកំរិតថ្នាក់នីមួយៗ ទាំងនៅមធ្យមសិក្សាបឋមភូមិ ទាំងនៅមធ្យមសិក្សាទុតិយភូមិ តាមលទ្ធភាពជាក់ស្តែង ដែលអាចធ្វើបាន ។
- ថ្នាក់សិស្សពូកែ តាមគ្រឹះស្ថានមធ្យមសិក្សានីមួយៗ អាចជ្រើសរើស និងរៀបចំតាមគំនិតច្នៃប្រឌិតផ្ទាល់របស់សាមីមូលដ្ឋានទោះតាមរូបភាពណាមួយក៏ដោយ ។
- ចំនួនសិស្សតាមថ្នាក់ពូកែ គប្បីរៀបចំក្នុងចំនួនមួយសមរម្យ និង តាមលទ្ធភាពជាក់ស្តែង ។
- គ្រូដែលបង្រៀនថ្នាក់សិស្សពូកែ គប្បីរកគ្រូដែលមានបទពិសោធន៍ និង ត្រូវបង្រៀនតាមរបបម៉ោងកំណត់ធម្មតា របស់គ្រូបង្រៀន ។
- ការសំរេចឲ្យឡើងថ្នាក់សិស្សពូកែ ខ្ពស់ជាងបន្តបន្ទាប់ ឬ ការបញ្ជូនឲ្យទៅរៀនថ្នាក់ធម្មតាវិញជា សមត្ថកិច្ចផ្ទាល់របស់គ្រឹះស្ថានមធ្យមសិក្សាគាំពារ ដោយពេលវេលាលក្ខណៈវិនិច្ឆ័យមួយច្បាស់លាស់ ដែលកើតឡើងពីគំនិតផ្តួចផ្តើមរបស់សាលារៀន ។

២- សិស្សពូកែប្រចាំខេត្ត-ក្រុង និង ប្រចាំគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ក្រសួងអប់រំ យុវជន និងកីឡា :

- នៅដើមខែឧសភាគ្រប់ខេត្ត-ក្រុង និងគ្រប់គ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ក្រសួងអប់រំ យុវជន និងកីឡា តាមលទ្ធភាព និង តាមគំនិត ច្នៃប្រឌិតផ្ទាល់ ត្រូវធ្វើការប្រឡងជ្រើសរើសសិស្សពូកែផ្នែក គណិតវិទ្យា និង អក្សរសិល្ប៍ខ្មែរថ្នាក់ទី៩ និង ទី១២ តាមចំនួនដូចតទៅ :

ក្រុម ក : ចំពោះខេត្ត-ក្រុងធំ រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ចាម បាត់ដំបង តាកែវ ព្រៃវែង ក្នុងមួយកំរិតថ្នាក់ និងមួយមុខវិជ្ជាចំនួន ៥ នាយក់ ។

ក្រុម ខ : ចំពោះខេត្ត-ក្រុងមធ្យមរួមមាន ខេត្តស្វាយរៀង ពោធិសាត់ កំពង់ធំ កំពត បន្ទាយមានជ័យ សៀមរាប ក្រចេះ កំពង់ឆ្នាំង កំពង់ស្ពឺ ក្រុងព្រះសីហនុ និង គ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា ក្នុងមួយកំរិតថ្នាក់ និង មួយមុខវិជ្ជាចំនួន ៣នាយក់ ។

ក្រុម គ : ចំពោះខេត្ត-ក្រុង តូច រួមមានខេត្ត ស្ទឹងត្រែង កោះកុង រតនគិរី មណ្ឌលគិរី ព្រះវិហារ ក្រុងកែប និង ក្រុងប៉ៃលិន ក្នុងមួយកំរិតថ្នាក់ និង មួយមុខវិជ្ជា ចំនួន ២ នាយក់ ។

-ដំណើរការប្រឡងជ្រើសរើសសិស្សពូកែ :

ធ្វើការប្រឡងលើមុខវិជ្ជាឯកទេស (គណិតវិទ្យា រឺអក្សរសិល្ប៍ខ្មែរ) ពីរពេល ដែលក្នុងមួយពេលមានថិរវេលា ៣ ម៉ោង ហើយ ប្រធានវិញ្ញាសាចេញដោយ មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង រឺ ដោយនាយកចំពោះគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ ក្រសួងអប់រំ យុវជន និងកីឡា ។

ធ្វើការប្រឡងលើមុខវិជ្ជា វប្បធម៌ទូទៅ (សីលធម៌ ពលរដ្ឋវិទ្យា និង អក្សរសិល្ប៍) មួយពេល មានថិរវេលា ២ ម៉ោង ហើយប្រធានវិញ្ញាសាចេញដោយមន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង ឬដោយនាយក ចំពោះគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ក្រសួងអប់រំ យុវជន និង កីឡា ។

វិញ្ញាសាវប្បធម៌ទូទៅគ្រាន់តែ ជាវិញ្ញាសាចម្រាញ់ប៉ុណ្ណោះ មានន័យថា បេក្ខជនណាដែលទទួលពិន្ទុចាប់ពីមធ្យមឡើងទៅលើមុខវិជ្ជាវប្បធម៌ទូទៅ ទើបត្រូវបានពិនិត្យ និងធ្វើជំរើសលើពិន្ទុនៃមុខវិជ្ជាឯកទេស ។ ប៉ុន្តែ ពិន្ទុវប្បធម៌ទូទៅ មិនបូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាឯកទេសឡើយ ។

-ក្រោយពីជ្រើសរើសបានសិស្សពូកែតាមចំនួនកំនត់រួចហើយ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និងគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ ក្រសួងអប់រំ យុវជន និង កីឡា ដែលមានសិស្សពូកែថ្នាក់ទី៩ និងថ្នាក់ទី១២ មុខវិជ្ជា គណិតវិទ្យា និងអក្សរសិល្ប៍ ត្រូវបញ្ជូនបញ្ជី រាយនាមសិស្សពូកែតាមមុខវិជ្ជា និងតាមកំរិតថ្នាក់ព្រមទាំងពាក្យសុំប្រឡងសិស្សពូកែ ទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ) ឲ្យបានមុនថ្ងៃទី១០ ខែឧសភា រៀងរាល់ឆ្នាំ ។

ឃ- ការប្រឡងជ្រើសរើសជ័យលាភីសិស្សពូកែទូទាំងប្រទេស :

- នៅចុងខែឧសភា ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ។ ថ្នាក់ទី៩ និងទី១២ មុខវិជ្ជា គណិតវិទ្យា និងអក្សរសិល្ប៍ (កាលបរិច្ឆេទនឹងត្រូវកំណត់ ច្បាស់លាស់សំរាប់ឆ្នាំនីមួយៗ) ។
- បេក្ខជនសិស្សពូកែទូទាំងប្រទេស អាចជ្រើសរើសយកបានតែមួយមុខវិជ្ជាប៉ុណ្ណោះ ។ បេក្ខជនម្នាក់ៗត្រូវប្រឡងបីពេល : ពីរពេលសំរាប់មុខវិជ្ជាដែលខ្លួនជ្រើសរើស និងមួយពេលសំរាប់វប្បធម៌ទូទៅ ។
- ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ចេញដោយក្រសួងអប់រំ យុវជន និងកីឡា ហើយការប្រឡងប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ទាំងវិញ្ញាសាសរសេរ ទាំងកំណែ ។
- ជ័យលាភីទូទាំងប្រទេសពីលេខ ១ ដល់លេខ ១០ នៃមុខវិជ្ជានីមួយៗ តាមកំរិតថ្នាក់នីមួយៗ នឹងត្រូវប្រកាសទទួលស្គាល់ជាផ្លូវការ ទទួលការសរសើរ រង្វាន់លើកទឹកចិត្ត និង អំណោយពីសប្បុរសជន ពីក្រសួងអប់រំ យុវជន និងកីឡា ។

- លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង និង លោកនាយកគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវចាត់តាំងមន្ត្រីអប់រំម្នាក់ ដើម្បីជូនដំណើរ និងគ្រប់គ្រងបេក្ខជន ។ សោហ៊ុយធ្វើដំណើរស្នាក់នៅ និង ហូបចុក របស់គណៈប្រតិភូ ដែលអញ្ជើញទៅចូលរួមការប្រឡង ឧបត្ថម្ភដោយក្រសួងអប់រំ យុវជន និងកីឡា ។
- ក្រសួងអប់រំយុវជន និងកីឡា សង្ឃឹមថា លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់ខេត្ត-ក្រុង លោកនាយកគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ ក្រសួង នឹងអនុវត្តតាមការណែនាំប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
តុល ឡោះ

★★★

[illegible]
[illegible] ០០៦.៩ [illegible]

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល